មាតិកា

I. ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១៩-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៧៥ ស្តីពី ការតែងតាំងលោកជំទាវ ជា នីតា និង ឯកឧត្តម ញឹម អន្តាមុស្ស ជាទីប្រឹក្សារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៩១៩២

១៩-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៧៦ ស្តីពី ការតែងតាំងឯកឧត្តម យស យុទ្ធី និង លោកជំទាវ កែវ សារឿន ជាទីប្រឹក្សាអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៩១៩៣

២០-១០-២០១០ -ព្រះរាជក្រឹត្យ នស/រកត/១០១០/៨០៩ ស្តីពី ការតែងតាំងឯកឧត្តម សុខ ផារិទ្ធិ និង ឯកឧត្តម ហួ ចំរើន ជាទីប្រឹក្សារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៩១៩៤

២៥-១០-២០១០ -ព្រះរាជក្រឹត្យ នស/រកត/១០១០/៨២៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ទីប្រឹក្សា,ជំនួយការ សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និង សប្បុរសជន ចំនួន ១៦២ រូប ៩១៩៥

១៨-១១-២០១០ -ព្រះរាជក្រឹត្យ នស/រកត/១១១០/៨៨៧ ស្តីពី ការតាំងស៊ប់មន្ត្រីរាជការរបស់ក្រសួង ស្ថាប័ន នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ចំនួន ១១១ នាក់ ៩១៩៩

១៨-១១-២០១០ -ព្រះរាជក្រឹត្យ នស/រកត/១១១០/៨៨៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ចំពោះ លោក Putu M.Kamayana នាយកធនាគារអភិវឌ្ឍអាស៊ី ប្រចាំប្រទេសកម្ពុជា ៩២០៤

១៨-១១-២០១០ -ព្រះរាជក្រឹត្យ នស/រកត/១១១០/៨៩០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះលោក អោម ហាត់ ប្រធានសាខាពន្ធដារ ខេត្តបន្ទាយមានជ័យ ៩២០៥

២៣-១១-២០១០ -ព្រះរាជក្រឹត្យ នស/រកត/១១១០/៨៩៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះលោកជំទាវ ឡោត ខេង និង ឯកឧត្តម យស ផានីត្ថា ៩២០៦

២៣-១១-២០១០-ព្រះរាជក្រឹត្យ នស/រកត/១១១០/៨៩៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ចំនួន ០៤ រូប ៩២០៧

២៣-១១-២០១០-ព្រះរាជក្រឹត្យ នស/រកត/១១១០/៨៩៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿង
ឥស្សរិយយស ជាតូបការ ចំពោះ ឯកឧត្តម ចំនួន ០២ រូប ៩២០៨

II. រាជរដ្ឋាភិបាល

អនុក្រឹត្យ

២៩-១១-២០១០-អនុក្រឹត្យលេខ ១៤៦ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៩២០៩
៣០-១១-២០១០-អនុក្រឹត្យលេខ ១៤៧ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៨.៩៧៧ ហិកតា
ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកសំបូរ ខេត្តក្រចេះ ៩២១១
៣០-១១-២០១០-អនុក្រឹត្យលេខ ១៤៨ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៩.៩៩៦ ហិកតា
ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកស្នួល ខេត្តក្រចេះ ៩២១៣
៣០-១១-២០១០-អនុក្រឹត្យលេខ ១៤៩ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ១.៩០០ ហិកតា
ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកអណ្តូងមាស ខេត្តរតនគីរី ៩២១៥
០៦-១២-២០១០-អនុក្រឹត្យលេខ ១៥០ អនក្រ.បក ស្តីពី ទិវាជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ ០៩ ធ្នូ ៩២១៨
០៦-១២-២០១០-អនុក្រឹត្យលេខ ១៥១ អនក្រ.បក ស្តីពី ការបណ្តុះបណ្តាលថ្នាក់បណ្ឌិត ៩២២០
២៥-១១-២០១០-អនុក្រឹត្យលេខ ១១៤១ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៩២៣៩
២៦-១១-២០១០-អនុក្រឹត្យលេខ ១១៤២ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៩២៤០
២៦-១១-២០១០-អនុក្រឹត្យលេខ ១១៤៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩២៥៣
២៦-១១-២០១០-អនុក្រឹត្យលេខ ១១៤៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩២៥៤
២៦-១១-២០១០-អនុក្រឹត្យលេខ ១១៤៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩២៥៥
២៦-១១-២០១០-អនុក្រឹត្យលេខ ១១៤៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩២៥៦
២៦-១១-២០១០-អនុក្រឹត្យលេខ ១១៤៧ អនក្រ.តត ស្តីពី ការបញ្ចប់មុខតំណែង ៩២៥៧
២៦-១១-២០១០-អនុក្រឹត្យលេខ ១១៤៨ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៩២៥៨
២៩-១១-២០១០-អនុក្រឹត្យលេខ ១១៤៩ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយស ស្ថាបនាជាតិ ៩២៥៩
៣០-១១-២០១០-អនុក្រឹត្យលេខ ១១៥០ អនក្រ.តត ស្តីពី ការតែងតាំងមុខងារ នាយទាហាន ៩២៦១
៣០-១១-២០១០-អនុក្រឹត្យលេខ ១១៥១ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៩២៦២
៣០-១១-២០១០-អនុក្រឹត្យលេខ ១១៥២ អនក្រ.តត ស្តីពី ការ ជូនមេដាយមុនីសារាភ័ណ្ឌ ៩២៦៣
៣០-១១-២០១០-អនុក្រឹត្យលេខ ១១៥៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩២៦៤

III ‐ការងារបណ្តាក្រសួង

១‐ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
និង
ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

០៨-១១-២០១០ -ប្រកាសអន្តរក្រសួងលេខ ៩៣៤ សហវ.ប្រក ស្តីពី ការកំណត់សួយសារខ្សាច់សំណង់ និង ខ្សាច់ល្បាយភក់ នាំចេញក្រៅប្រទេស ៩២៦៦

២‐ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១៨-១១-២០១០ -ប្រកាសលេខ ៩៣១ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្វេរីវេបិល ស៊ីខឹមស្ទេនស៍ ខមភេនី លីមីធីត បង្កើតរោងចក្រ ផលិតថង់ប្លាស្ទិកគ្រប់ប្រភេទ,ថង់ និង ការ៉ុងប្លាស្ទិកដាក់សំរាម និង សន្លឹកប្លាស្ទិក ៩២៦៩

១៨-១១-២០១០ -ប្រកាសលេខ ៩៣២ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ភ្នំពេញ បៀរ បង្កើតរោងចក្រ ផលិតស្រាបៀរ ៩២៧៣

១៨-១១-២០១០ -ប្រកាសលេខ ៩៣៣ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ប៊ួមីង ថេកស្តាយ ខបភើរេសិន បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៩២៧៧

៣‐ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

១៧-១១-២០១០-សេចក្តីណែនាំលេខ ០២៩ សណន ស្តីពីវិធានការពង្រឹងការអនុវត្តការងារស្ថិតិ និង អត្រានុកូលដ្ឋាន ៩២៨១

៤‐ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៥-០២-២០១០ -លិខិតបញ្ជាក់លេខ ០៧៩៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ផេស៊ីហ្វិក អិមខេ ខមភេនី អិលធីឌី** ៩២៨៨

១៥-០២-២០១០ -លិខិតបញ្ជាក់លេខ ០៧៩៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ីសធើន ឌើលខ៉ាយន៍ ឡូជីស្ទិក (ខេមបូឌា) អិលធីឌី** ៩២៩០

១៥-០២-២០១០ -លិខិតបញ្ជាក់លេខ ០៨០០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជេត ហ្វូលឌីង អ៊ិនធើណេសិនណល សាមីនីង** ៩២៩២

១៥-០២-២០១០ -លិខិតបញ្ជាក់លេខ ០៨០១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **លី គីមស៊ុន អ៊ីមផត អិចផត** ៩២៩៤

១៥-០២-២០១០ -លិខិតបញ្ជាក់លេខ ០៨០៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ 2 ខេ អ៊ិនវេសមេន** ៩២៩៦

១៥-០២-២០១០ -លិខិតបញ្ជាក់លេខ ០៨០៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អអិនអ អ៊ិមផត អិចផត** ៩២៩៨

១៥-០២-២០១០ -លិខិតបញ្ជាក់លេខ ០៨១៤ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែ សហគ្រាសឯកបុគ្គល និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជី អេច មេឌា & អ៊ែតវើថាយស៊ីង ប្រដាក់សិន** ៩៣០០

១៥-០២-២០១០ -លិខិតបញ្ជាក់លេខ ០៨១៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌី សំណាង គ្រុប** ៩៣០២

១៦-០២-២០១០ -លិខិតបញ្ជាក់លេខ ០៨២៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជី ប្រូមីស ដេវលប៍ មីសិន ខបភើរេសិន** ៩៣០៤

១៦-០២-២០១០ -លិខិតបញ្ជាក់លេខ ០៨៣១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **តាខ៉ាត់សេម** ៩៣០៦

ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៧៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃការបោះឆ្នោតជ្រើសរើស ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា នាសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី២ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១: តែងតាំងលោកជំទាវ **ជា នីតា** និងឯកឧត្តម **ញ៉ឹម អន្តាបុស្ស** ជាទីប្រឹក្សារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាមានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

មាត្រា២: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ចករ

៣៧. ១០០៩. ៦៩០ **នរោត្តម សីហមុនី**

លេខ: ៨១១ ច.ល

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០១០

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ ធ្នូ ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិនគេន

ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៧៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃការបោះឆ្នោតជ្រើសរើស ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា នាសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី២ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១. តែងតាំងឯកឧត្តម យស យុទ្ធី និងលោកជំទាវ កែវ សាវឿន ជាទីប្រឹក្សាអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

មាត្រា២. តម្លើងឋានៈជូនឯកឧត្តម **អេលីត កុសលបុត្រ** ទីប្រឹក្សាអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានឋានៈស្មើ **រដ្ឋលេខាធិការ**

មាត្រា៣. ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣/ល.២០០៩.៦៩១

នរោត្តម សីហមុនី

លេខ:៨៧០ ច.ល

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០១០

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី០៣ ខែ ធ្នូ ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនគេន

ព្រះរាជក្រឹត្យ

នស/រកត/១០១០/៩០៩

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃការបោះឆ្នោតជ្រើសរើស ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា នាសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី២ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១: តែងតាំងឯកឧត្តម **សុខ ផារិទ្ធ** និងឯកឧត្តម **ហួ ចំរើន** ជាទីប្រឹក្សារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.១០១០.៩២៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១០

លេខ: ៨១៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១០១០/៩២៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ទីប្រឹក្សា, ជំនួយការ **សម្តេចអគ្គមហាធម្មពោធិសាល** ប្រធានព្រឹទ្ធសភា
និងសប្បុរសជន ចំនួន ១៦២ រូប បានបំពេញការងារ និងចូលរួមកសាងអភិវឌ្ឍន៍ប្រទេសជាតិ

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- ឯកឧត្តមបណ្ឌិត	អន	ប៊ុណ្ណារឿន	២- ឯកឧត្តម	គុជ	ស៊ីនិត
៣- ឯកឧត្តម	សុខ	រឿន	៤- ឯកឧត្តម	ចៅ	សុធី
៥- ឯកឧត្តម	ប៊ុន	វុទ្ធា	៦- ឯកឧត្តម	បែល	សុខុម
៧- ឯកឧត្តម	សៀវ	សៃ	៨- ឯកឧត្តម	ទីម	ប៊ុនណា
៩- ឯកឧត្តម	ប៉ុល	សុគន្ធ	១០- ឯកឧត្តម	ហាក់	សុវណ្ណា
១១- ឯកឧត្តម	ថេង	សុផុល	១២- ឯកឧត្តម	ខួង	លាង
១៣- ឯកឧត្តមឧកញ៉ា	ជួប	ច័ន្ទ	១៤- ឯកឧត្តមបណ្ឌិត	ឯក	វីរជេដ្ឋ
១៥- ឯកឧត្តម	ផាន់	សុភាព	១៦- ឯកឧត្តម	អ៊ុច	សុផល
១៧- ឯកឧត្តម	ស៊ឹម	គឹមសែន	១៨- ឯកឧត្តម	ទេព	ចាន់អុនវុធិរក្ស
១៩- ឯកឧត្តមឧកញ៉ា	ងិន	ស្រៀន	២០- ឯកឧត្តម	លឹម	មុនិន្ទ
២១- វរសេនីយ៍ឯក	ឡោ	វណ្ណចក្រ	២២- លោកជំទាវ	ទិត្យ	ច័ន្ទតារីន
២៣- លោក	កែន	សម្បត្តិ	២៤- លោក	ទន់	ប៊ុនធឿន
២៥- លោក	នួន	ឆនលាភ	២៦- លោក	ទិត្យ	ច័ន្ទគិរី
២៧- លោក	សុខ	ខេមរិន	២៨- លោក	ស៊ុន	ស៊ីថា
២៩- លោក	អ៊ឹង	លីសៀក	៣០- លោក	ឌុក	ណារិន
៣១- លោក	កែ	សាខន	៣២- លោក	ស៊ីវ	សារឹម
៣៣- លោក	អ៊ឹង	វីរៈ	៣៤- លោក	ហ៊ុន	ជា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ខ-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានីព្រះស៊ីសុវត្ថិ មុនីវង្សកុសមៈនារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- ឯកឧត្តមឧកញ៉ា	ឡេង	ប៊ុនតេង	២- ឯកឧត្តម	ពេជ្រ	គឹមស្រ៊ាង
៣- ឯកឧត្តម	ហាក់	ប៊ុនធឿន	៤- លោកជំទាវ ផេង		គន្ធាបូរី
៥- ឯកឧត្តម	ផាន់	វណ្ណារ៉េត	៦- លោកឧកញ៉ា លឹម		ប៊ុនសួរ
៧- លោកឧកញ៉ា	លឹម	រស់	៨- លោកឧកញ៉ា ហាន់		ឃាង
៩- ឯកឧត្តម	ឌួង	អេលីត	១០- ឯកឧត្តម គង់		ប៊ូល
១១-ឯកឧត្តម	សយ	កុសល			

គ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- ឯកឧត្តម	ប៉ាល់	ចន្ទតារា	២- លោកវេជ្ជបណ្ឌិត តួច		ប៊ូលីវ៉ា

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១- ឯកឧត្តមឧកញ៉ា	ឈឹម	មនោ	២- ឯកឧត្តម	លន់	មុនីរតនា
៣- ឯកឧត្តម	អេលីត	កុសលបុត្រ	៤- លោកជំទាវ	ជា	នីតា
៥- លោកជំទាវ	សុច	សុធា	៦- លោកជំទាវ	ប្រាក់	ច័ន្ទណយ
៧- ឯកឧត្តម	ច័ន្ទ	ប៊ុនថុល	៨- ឯកឧត្តម	ចេង	ហុង
៩- ឯកឧត្តម	បេ	សុខឡេង	១០- ឯកឧត្តម	ហាន់	វុទ្ធី
១១- ឯកឧត្តម	ឃ្លោក	សារុន	១២- ឯកឧត្តម	សិរិទ្ធ	សាម៉ន
១៣- ឯកឧត្តម	លី	ណុប	១៤- ឯកឧត្តម	កៅ	ថាច
១៥- ឯកឧត្តម	ហ៊ុល	សាភា	១៦- ឯកឧត្តមឧកញ៉ា	សុខ	ហួត
១៧- ឯកឧត្តម	ឈឹម	សុទ្ធគុណ	១៨- ឯកឧត្តម	ពៅ	ណារិទ្ធ
១៩- ឯកឧត្តម	ហេង	សុភារិទ្ធ	២០- លោក	លឹម	លីសេង
២១- លោក	អ៊ូ	វីភព	២២- លោក	ធី	សុគន្ធ
២៣- លោក	កែវ	ឈុនលី	២៤- លោក	ព្រាប	មុនី
២៥- លោក	ស៊ាង	សុវណ្ណ	២៦- លោក	គឹម	ពិសិដ្ឋ
២៧- លោក	គ្រុយ	លឹមហេង	២៨- លោក	មាស	សុវណ្ណា
២៩- លោក	សុខ	ហេង	៣០- លោក	ទួន	ប៊ុក
៣១- លោក	នៅ	វៃ	៣២- លោក	មាត	ឆរស្មី
៣៣- លោកបណ្ឌិត	សារិន	ដេណូវ៉ា	៣៤- លោក	ជៀក	វ៉ាន់ធី
៣៥- លោក	គង់	ហម	៣៦- លោក	ជា	ផានិត
៣៧- លោក	ហែម	ថ្លៃថ្លា	៣៨- លោក	លឹម	វណ្ណា
៣៩- លោក	អ៊ិន	មាត្រា	៤០- លោក	មុត	សុខឃាន់
៤១- លោក	ហ៊ាង	ថារ៉េត	៤២- លោក	ហេង	ភារុន

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៤៣- លោក	ទូច	ពិនតារា	៤៤- លោក	គឹម	សុផាត
៤៥- លោក	ហួត	ឈួរ	៤៦- លោក	មិន	សុវណ្ណា
៤៧- លោក	ឡេង	ចាន់វិរៈ	៤៨- លោក	ស៊ឹម	ចាន់ណារ៉ា
៤៩- លោក	គ្រឹះ	យុទ្ធគុណ	៥០- លោក	ជា	សារិន
៥១- លោក	អៀម	សុផល	៥២- លោក	ប៉ាង	ឡាឌី
៥៣- លោក	សម	ភារា	៥៤- លោក	លាវ	ស៊ុនលី
៥៥- លោកស្រី	អ៊ុំ	ប្រណី	៥៦- លោក	ជ	គឹមស៊ី
៥៧- លោក	ស៊ឹម	សំអាត	៥៨- លោក	ហ៊ុន	មុន្នីរ័ត្ន
៥៩- លោក	ឆ្លូវ	សុធីរ៉ា	៦០- លោក	ទុយ	ប៊ុនសេរីរ័ត្នមុនី

ង-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា** :

១- ឯកឧត្តម	ម៉ៅ	សុវត្ថារ៉ា	២- ឯកឧត្តម	សុត	រស្មី
៣- ឯកឧត្តម	ឯម	សុនី	៤- ឯកឧត្តម	ថាច់	វណ្ណៈ
៥- លោកជំទាវ	កែវ	រស្មី	៦- លោក	ឯម	វិចិត្រ
៧- លោក	អំ	ប៊ុនលី			

ច-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ** :

១- ឯកឧត្តម	គឹម	ជាតិ	២- ឯកឧត្តម	ផេង	សុគន្ធារិទ្ធ
៣- ឯកឧត្តម	ប៊ុន	វុទ្ធី	៤- ឯកឧត្តម	ថាច់	ថង
៥- ឯកឧត្តម	ហា	មាន	៦- លោកជំទាវ	ហម	សុធារី
៧- លោកជំទាវ	ភួង	ម៉ាឡា	៨- លោកជំទាវ	សុវណ្ណ	រំដួល
៩- ឯកឧត្តម	អ៊ិត	វ៉ាសនា	១០- ឯកឧត្តម	ចាន់	កុលបុត្រ
១១- លោក	ឡេង	ជ្រិន	១២- លោក	អ៊ូ	សំណាង
១៣- លោក	ម៉ី	ចំរើន	១៤- លោក	ហាញ់	សុបិន្ត
១៥- លោក	ស្រ៊ុន	សុភ័ក្រ្ត	១៦- លោកស្រី	វ៉ាន់	ថា
១៧- លោក	វេង	ចក់	១៨- លោក	ស៊ឹម	ប៊ុតបណ្ឌិត
១៩- លោក	ឆេង	ជៀក	២០- លោក	អ៊ុក	ខេមា
២១- លោក	ប៉ាក់	យូលាង	២២- លោក	សុវណ្ណ	ច័ន្ទផានិត
២៣- លោក	គង់	សំអន	២៤- លោក	សុខ	ផារិទ្ធ
២៥- លោក	អ៊ុក	ច័ន្ទកុសល	២៦- លោក	ហង្ស	សុផារិទ្ធ
២៧- លោក	ជិន	ភារម្យ	២៨- លោក	ខៀវ	គារុធ
២៩- លោក	ឆែម	សុខុន	៣០- លោក	ប៊ិន	សម្បត្តិថារ៉ា
៣១- លោក	ឈៀង	សែ	៣២- លោក	ប៉ែន	ច័ន្ទសុខខេមរិទ្ធ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៣៣- លោក	ឆាយ	ពុធផល្លា		៣៤- លោក	ហ៊ិន	វិបុល
៣៥- លោក	កែវ	សារុន		៣៦- លោកស្រី	ទេព	ប៊ុណ្ណារី

ឆ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :

១- លោក	សុខ	លាងហុក	២- លោក	ម៉ាក់	គន្ធា
៣- លោក	វ៉ា	ឃុត	៤- លោក	អ៊ឹង	ផល្លី
៥- លោក	ផេង	ឈុន	៦- លោក	ទឿ	តាំងសារ៉ូ
៧- លោក	ឡេង	ឃាង	៨- លោក	សេង	ថង
៩- លោក	ស៊ូ	សារិន	១០- លោក	អ៊ូ	ពៅ
១១- លោក	ណុប	នាង	១២- លោក	សាន់	គីមឡឿន

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រល. ១០៧០.៩៣៩

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០

លេខ: ៨១៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនអេន

ព្រះរាជក្រឹត្យ

នស/រកត/១១១០/៩៩៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតាំងស៊ប់មន្ត្រីរាជការរបស់ក្រសួង ស្ថាប័ន នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដូចមានរាយនាមខាងក្រោម:

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ				
តាំងស៊ប់គិតចាប់ពីថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១០				
១	**ជា សុរី**	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL ★

២	ម៉ី ចន្ទបណ្ឌិត	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣	ម៉ូង រ៉ាន់	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៤	ម្លូង់ តារា	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៥	ស៊ឹម ឈុន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៦	សុខ ថា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៧	ឃឿន ច័ន្ទមុនីភា	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៨	តាំង ចរិយា	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៩	តាន់ លីនណា	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១០	សុខ លក្ខិណា	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១១	ឡេង ស៊ុនសាហ្វារី	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១២	អៀង សុលីដា	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៣	ហ៊ី ចាន់ដែត	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៤	ឡៅ គីមសល្យ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៥	សេង សុខហេង	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៦	ឌូ សុគន្ធា	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៧	ខេង តារា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៨	ផុន សុតា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៩	ប៉ែន ស៊ីនួន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២០	ធឿន ច័ន្ទសុជាតិ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២១	ជុំ និមល	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២២	សាម គីមហុង	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២៣	សេក សំរិទ្ធ	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២៤	ចាន់ សំរិទ្ធ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២៥	ធួង សំណាង	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២៦	ផល្លា ច័ន្ទពិសិដ្ឋ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២៧	រស់ ចន្ថា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២៨	សំឡុក សីម៉ា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២៩	ចន ទៃ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣០	អ៊ុក គីមស៊ីម	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣១	សាយ ប៊ុនបញ្ញា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣២	ហ៊ី សិលា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣៣	ជា មករា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៣៤	ហាក់ អាវីហ្វីន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣៥	សេង ច័ន្ទសីហា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣៦	អ៊ុក សុផល	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣៧	សិរី មករា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
តាំងស៊ប់គិតចាប់ពីថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១០				
១	ម៉ុន ជួន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២	វាសនា ជីវី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣	ស៊ីវ សុខលីន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៤	នេព គង់	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៥	រឿន ស្រ៊ន់	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៦	ពុយ ចាន់ធឿន	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៧	ស៊ុន សុផារី	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៨	អ៊ាប សុវណ្ណា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៩	ពៅ ប៊ុណ្ណារ័ត្ន	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១០	ជា ច័ន្ទចរិយា	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១១	សក់ ដាវីត	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១២	ហៀប មានិត	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៣	ឌឹក សុភាស់	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៤	ហាត ឡេងមុរេន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៥	ម៉ម ប៊ុណ្ណារ៉េត	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៦	ប៉ែន សុខន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៧	ប៉ូ វណ្ណារ៉េត	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៨	ហឿង ប៉ូលីន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៩	លី ប៊ុរ៉ា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២០	អ៊ុង ច័ន្ទរតនា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
តាំងស៊ប់គិតចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៧				
១	ស្រ៊ី អេងលី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
តាំងស៊ប់គិតចាប់ពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១០				
១	លឿង សោភា	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២	វង្ស សាវិន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣	សុត សុធា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៤	ហួរ ចាន់លោង	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៥	ឌិន ច័ន្ទឌី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៦	គិន សីហា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៧	បឿន ប៊ិន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៨	ម៉ូ យុទ្ធី	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៩	ប៉ែន ពេញ	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១០	ផុន វិចិត្រ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១១	វ៉ា លីមអ៊ន់	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១២	ស៊ុន ស៊ីដេត	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៣	អ៊ុង សុវណ្ណា	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៤	ម៉ាច សុភ័ក្រ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៥	ទូច ប៊ុនរ័ត្ន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៦	អន ប៊ូរ៉ា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៧	ឡាច វណ្ណាស័ក្តិ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៨	ប៊ិន ប៊ុនឡុង	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
តាំងស៊ប់គិតចាប់ពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១០				
១	សាំង យី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២	កែវ រ័ត្នវិសាល	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣	នេព សុនីតា	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៤	ហេង គីមសាន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៥	សាន់ សៅឌីណា	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៦	ប៉ោ សោភ័ណា	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៧	តាំង ដា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៨	អ៊ឹង ប៊ុំហេង	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច				
តាំងស៊ប់គិតចាប់ពីថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១០				
១	ត្លុក សុគន្ធា	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២	ហ៊ុក ចាន់ឡេង	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣	ខែម សារ៉ា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៤	សៀង ទុដ្ឋា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៥	ផាត់ រិន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
[illegible]	នង សុភាព	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៧	នេត្រ វ៉ាខេន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

៨	ខែម ពុធទាសនា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៩	អ៊ុច ម៉ែនសុលីដា	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១០	ថាត់ ច័ន្ទតុលា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១១	ម៉ៅ សម្បត្តិ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១២	ម៉ឹម កែវមរកត	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៣	គីម គន្ធីតា	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៤	សៀង ផេងវី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៥	ម៉ែន ចិន្ត្រា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៦	ជាន ចរិយា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៧	ប៊ុត វ៉ាន់ដេត	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៨	ហៅ គីមី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៩	គិញ ខន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២០	ស៊ុំ សុខជា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២១	ឡឹក សុធារ៉ា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២២	ចាប សោភក្រ្ត	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២៣	ពៅ សុភាព	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២៤	លឹម សុខគុណា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២៥	ម៉េង ផេង សៀន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២៦	ឈៀង សីហា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២៧	ចាន់ សុខា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសាផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

ពរ/ណ.១០១១.៩០៣

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១០

លេខៈ ៧៩៤ ច.ល

ដើម្បីចម្លងចែក

៥ / ៥

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនគេន

ព្រះរាជក្រឹត្យ

នស/រកត/១១១០/៩៩៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា

ចំពោះ

លោក Putu M.Kamayana

នាយកធនាគារអភិវឌ្ឍអាស៊ីប្រចាំប្រទេសកម្ពុជា ដែលបានខិតខំប្រឹងប្រែងជំរុញការអភិវឌ្ឍមូលដ្ឋានទាំង ៣៧ របស់ខេត្តទាំង ០៥ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តសៀមរាប និង ខេត្តកំពង់ធំ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រ.ល.១០១១.៩០៥

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១០

លេខ:៧៩៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១១០/៩៩០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

ចំពោះ

លោក អោម ហាក់

ប្រធានសាខាពន្ធដារ ខេត្តបន្ទាយមានជ័យ មានគុណបំណាច់
និងស្នាដៃល្អក្នុងការបំពេញភារកិច្ច ជូនជាតិមាតុភូមិ កន្លងមក

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រល. ១០១១. ៩០៦

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១០

លេខ: ៧៩៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ វិច្ឆិកា ឆ្នាំ២០១០

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ឌិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១១០/៩៩៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ហូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ០២ រូប ដែលមានស្នាដៃ ក្នុងការចូលរួមកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- លោកជំទាវ ឡោក ខេង

២- ឯកឧត្តម យស ផានីត្តា

ព្រះហស្តលេខា និងព្រះរាជលញ្ចករ
នរោត្តម សីហមុនី

៣រ.ល. ១០១១.៩២០

លេខៈ៩០៥ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១០

បានឃើញចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុយ ប៊ុនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១១០/៨៩៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ចំនួន០៤រូប មានស្នាដៃល្អនិងគុណបំណាច់ខ្ពស់ ក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ កន្លងមក

នូវ

ក-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :

លោក អ៊ាន់ ចំនួតារា

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

១- ឯកឧត្តម អ៊ិត រ៉ាឌី

២- លោកជំទាវ ពុំ ចាន់ធីនី

៣- ឯកឧត្តម ហង្ស ឡារ៉ាម៉ានី

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល. ១០១១. ៩១១

លេខ:៧៩៨ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១០

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ វិច្ឆិកា ឆ្នាំ២០១០
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
ប៊ិន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១១០/៩៩៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម ចំនួន ០២ រូប ដែលមានគុណបំណាច់ដ៏ឧត្តុង្គឧត្តម ចំពោះជាតិមាតុភូមិ
ព្រមទាំងបានបំពេញតួនាទីភារកិច្ច សំរេចបានលទ្ធផលគួរជាទីពេញចិត្ត :

១- ឯកឧត្តម ឯក សំអូល
២- ឯកឧត្តម ឌិត មុន្នី

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣៤៧. ១០១១. ៩១៣ នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១០

លេខ: ៧៩៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០១០
អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៤៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ , ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ , ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០១០
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក , ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋាន មួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣៨ អនក្រ.បក. ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០១០
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ២៨៦ លានរៀល (ពីររយសែសិបប្រាំមួយលានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦០ (ការទិញ) ជូនក្រុមប្រឹក្សាធម្មនុញ្ញ សំរាប់ការគ្រប់គ្រងឆ្នាំ ២០១០ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់ចំណាយទិញរថយន្តចំនួន ០៣ គ្រឿង ជូនសមាជិក សមាជិកា ថ្មី ៣ រូប នៃក្រុមប្រឹក្សាធម្មនុញ្ញ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ ✓

បានយកសេចក្តីជំរាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៨៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៨.៩៧៧ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកសំបូរ ខេត្តក្រចេះ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

ស ម្រេ ច

មាត្រា១:-

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៨.៩៧៧ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំរលួសមានជ័យ ស្រុកសំបូរ ខេត្តក្រចេះ ដើម្បីធ្វើការវិនិយោគដាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកាលេខ ១៦៤៩ ចណ.ក្រច ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០ របស់សាលាខេត្តក្រចេះ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា២:-

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍ របស់រាជរដ្ឋាភិបាល ។

មាត្រា៣:-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៤-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៤៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៩.៩៩៦ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកស្នួល ខេត្តក្រចេះ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងប្បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

ស ម្រេ ច

មាត្រា១: -

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៩.៩៥៦ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំស្នួល ឃុំស្រែចារ និងឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ ដើម្បីធ្វើការវិនិយោគដាំកៅស៊ូ ម៉ៃសាក់ និង អាកាស្យា ដូចមានក្នុងផែនទីជូនភ្ជាប់មកជាមួយ និងនិយាមកាដូចខាងក្រោម :

X	៦៤៧៩៩៨	Y	១៣៣៧១៤៣
X	៦៣៧៣៦៧	Y	១៣៣៧១០៨
X	៦៤៩៤៩៤	Y	១៣៥២៤៧៦
X	៦៤៩៥១៦	Y	១៣៥២៩៦៨
X	៦៤៩៤៩៤	Y	១៣៥០០០០
X	៦៤៨០០៤	Y	១៣៤៨០២៥
X	៦៤៨០០៤	Y	១៣៤៨០២៥
X	៦៥១៩៨២	Y	១៣៤៨០២៥

មាត្រា២: -

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍ របស់រាជរដ្ឋាភិបាល ។

មាត្រា៣: -

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៤ -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤៩ .អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ១.៩០០ ហិកតា

ស្ថិតនៅឃុំឧត្តមសោរ្ស ស្រុកអណ្តូងមាស ខេត្តរតនគិរី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងប្បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា១: -

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ១.៩០០ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំម៉ាលិក និង ឃុំញ៉ាង ស្រុកអណ្ដូងមាស ខេត្តរតនគិរី ដើម្បីធ្វើការវិនិយោគដាំកៅស៊ូ ដូចមានក្នុងផែនទី និង និយាមកាលេខ ១៣០៨/១០ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០ របស់សាលាខេត្តរតនគិរី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា២: -

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្រប តាមច្បាប់ និងគោលការណ៍ របស់រាជរដ្ឋាភិបាល ។

មាត្រា៣: -

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៤ -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្តរតនគិរី ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ២០១០

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

ផែនទី: ចំណុចគោលព្រំដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ជាំងលី (អ៊ិនធើសេចន) ខូអិលធីឌី ស្ថិតនៅក្នុងស្រុកអណ្តូងមាស ខេត្តរតនគិរី



ចំណុចដែលក្រុមការងារពិនិត្យឃើញ			
N	X	Y	ការពិព្ណនា
1	748574	1527688	ចំការស្វាយឈើ
2	748512	1527550	ចំការស្វាយឈើ
3	749347	1527354	ទីភូមិ
4	749182	1527095	ព្រៃឈើកាប់រាន
5	749118	1527074	ព្រៃឈើកាប់រាន
6	748897	1526995	ព្រៃឈើកាប់រាន
7	750500	1529500	ព្រៃឈើកាប់រាន
8	750897	1530755	ចំការស្វាយឈើ
9	752576	1532909	ចំការស្វាយឈើ
10	753358	1532640	ចំការស្វាយឈើ
11	753751	1532292	ចំការស្វាយឈើ
12	753829	1532217	ចំការស្វាយឈើ
13	750018	1527827	ទីភូមិ
14	750301	1527917	ទីភូមិ
15	750061	1527638	ព្រៃឈើកាប់រាន
16	750650	1527878	ព្រៃឈើកាប់រាន
17	750727	1528089	បង្គោលព្រំ.រ.ក
18	750894	1528123	បង្គោលព្រំ.រ.ក
19	751050	1528755	ព្រៃឈើកាប់រាន
20	751112	1528441	ព្រៃឈើកាប់រាន
21	750307	1530257	ព្រៃឈើកាប់រាន
22	750520	1529905	ព្រៃឈើកាប់រាន
23	750331	1530059	ព្រៃឈើកាប់រាន
24	750698	1530013	ចំការកៅស៊ូ
25	750750	1530407	ចំការកៅស៊ូ
26	751214	1530118	ចំការកៅស៊ូ
27	751102	1529818	ចំការកៅស៊ូ
28	751168	1529574	ចំការកៅស៊ូ
29	750753	1529536	ចំការកៅស៊ូ
30	751008	1529082	ចំការកៅស៊ូ
31	750464	1530669	ចំការស្វាយឈើ
32	750030	1529909	ផ្ទះនិងចំការជនជាតិ
33	750134	1529979	ផ្ទះនិងចំការជនជាតិ
34	750080	1529994	ផ្ទះនិងចំការជនជាតិ
35	751051	1530457	ចំការស្វាយឈើ
36	751297	1529606	ចំការស្វាយឈើ
37	751275	1529920	ចំការស្វាយឈើ
38	751350	1528514	ព្រៃឈើកាប់រាន
39	749996	1530532	ព្រៃឈើកាប់រាន
40	750118	1530541	ព្រៃឈើកាប់រាន

Coordinate System
Horizontal Datum : Indian 1960
Zone : 48
Projection : UTM
Spheroid : Everest

Scale: 1:50,000
0 500 1,000 M

លេខ: ...
បានឃើញ និង ឯកភាព
សូមគោរពជូន ឯកឧត្តមអភិបាលខេត្តរតនគិរី និង សំរេច
អណ្តូងមាស ថ្ងៃទី...ខែ...ឆ្នាំ ២០១០
អភិបាលស្រុក
[illegible] ជារិទ្ធ

លេខ: ...
បានឃើញ និង ឯកភាព
សូមគោរពជូន ឯកឧត្តមអភិបាលខេត្តរតនគិរី និង សំរេច
រតនគិរី ថ្ងៃទី...ខែ...ឆ្នាំ ២០១០
ប្រធានមន្ទីរកសិកម្មខេត្ត
សយ សុវណ្ណា

លេខ: ...
បានឃើញ និង ឯកភាព
សូមគោរពជូន ឯកឧត្តមអភិបាលខេត្តរតនគិរី និង សំរេច
រតនគិរី ថ្ងៃទី...ខែ...ឆ្នាំ ២០១០
ប្រធានមន្ទីរដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត
ទីម ស៊ីណាត

លេខ: ...
បានឃើញ និង ឯកភាព
គោរពជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និង នេសាទ ពិនិត្យ និង សំរេច
រតនគិរី ថ្ងៃទី...ខែ...ឆ្នាំ ២០១០
អភិបាលខេត្ត
ម៉ៅ សាវុធ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៥០ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ទិវាជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ ០៩ ធ្នូ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ

-យោងតាមតម្រូវការចាំបាច់

សម្រេច

មាត្រា ១.-

ត្រូវបានកំណត់យកថ្ងៃទី០៩ ធ្នូ រៀងរាល់ឆ្នាំ ជាទិវាជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ ស្របតាមសេចក្តីសម្រេចលេខ ៥៨/៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ របស់មហាសន្និបាតអង្គការសហប្រជាជាតិ។

មាត្រា ២.-

ទិវាជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ ត្រូវបានបង្កើតឡើងក្នុងគោលបំណង៖

-ចូលរួមក្នុងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ

-លើកកម្ពស់ប្រសិទ្ធភាពសេវាគ្រប់បែបយ៉ាង ពង្រឹងអភិបាលកិច្ច និងនីតិរដ្ឋនៅក្នុងការដឹកនាំ និងការគ្រប់គ្រងរដ្ឋ ព្រមទាំងរក្សាភាពស្អាតស្អំ និងយុត្តិធម៌ ដែលជាមូលដ្ឋានចាំបាច់ក្នុងការអភិវឌ្ឍសង្គមជាតិ និងកាត់បន្ថយភាពក្រីក្រ

-បង្កើនការគាំទ្រពីមហាជន និងលើកកំពស់ស្មារតីចូលរួមប្រយុទ្ធប្រឆាំងអំពើពុករលួយ

-កសាងជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋ លើការដឹកនាំរបស់រាជរដ្ឋាភិបាល

-អប់រំ ផ្សព្វផ្សាយពីផលវិបាកនៃអំពើពុករលួយ។

មាត្រា ៣.-

អង្គភាពប្រឆាំងអំពើពុករលួយទទួលបន្ទុករៀបចំចាត់ចែងកិច្ចការនៃទិវានេះ ដោយរួមសហការជាមួយនឹងក្រសួង ស្ថាប័ន អង្គភាពសាធារណៈ និងឯកជនគ្រប់លំដាប់ថ្នាក់ ដើម្បីរួមគ្នាបំផុសចលនាមហាជនគ្រប់មជ្ឈដ្ឋានឲ្យចូលរួមប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយឲ្យមានលក្ខណៈឧឡារិក។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានី-ខេត្ត និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល៖</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៥១ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការបណ្តុះបណ្តាលថ្នាក់បណ្ឌិត

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/៣៤៩ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាជាតិអប់រំ
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាជាតិអប់រំ

- បានឃើញអនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំគោលការណ៍ណែនាំ និងនីតិវិធីក្នុងការដឹកនាំការការពារសារណានិងនិក្ខេបបទ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១០

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីលក្ខខណ្ឌ និងយន្តការត្រួតពិនិត្យ សម្រាប់ដំណើរការបណ្តុះបណ្តាលថ្នាក់បណ្ឌិតប្រកបដោយប្រសិទ្ធភាព។

មាត្រា ២.-

អនុក្រឹត្យនេះ មានគោលបំណងដូចតទៅ៖

- បង្កើន និងធានាគុណភាពនិងធ្វើឯកភាពនីយកម្ម ក្នុងការបណ្តុះបណ្តាលថ្នាក់បណ្ឌិត
- ជួយគ្រឹះស្ថានឧត្តមសិក្សារដ្ឋនិងឯកជន ឲ្យមានភាពងាយស្រួល ក្នុងការរៀបចំការបណ្តុះបណ្តាលថ្នាក់បណ្ឌិត
- ជំរុញនិងលើកទឹកចិត្តចំពោះការស្រាវជ្រាវ។

មាត្រា ៣.-

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់គ្រឹះស្ថានឧត្តមសិក្សា ដែលធ្វើការបណ្តុះបណ្តាលថ្នាក់បណ្ឌិតនៅព្រះរាជាណាចក្រកម្ពុជា។

ជំពូកទី២

ប្រភេទសញ្ញាបត្របណ្ឌិត

មាត្រា ៤.-

សញ្ញាបត្របណ្ឌិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ចែកចេញជាពីរប្រភេទ ដូចខាងក្រោម៖

- សញ្ញាបត្របណ្ឌិតស្រាវជ្រាវ ជាប្រភេទសញ្ញាបត្រឧត្តមសិក្សាកម្រិតខ្ពស់បំផុត ដែលត្រូវបានប្រគល់ជូនទៅបុគ្គលណាម្នាក់ ដោយផ្អែកលើការទទួលស្គាល់ស្នាដៃថ្មី ទាំងខាងវិធីសាស្ត្រស្រាវជ្រាវ ទាំងខាងលទ្ធផលនៃការស្រាវជ្រាវ ដែលអាចបោះពុម្ពផ្សាយក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រ ព្រមទាំងមានការរួមចំណែកក្នុងការសិក្សាស្រាវជ្រាវ សម្រាប់ការបង្កើតចំណេះដឹងនិងការអនុវត្តថ្មី។
- សញ្ញាបត្របណ្ឌិតវិជ្ជាជីវៈ ជាប្រភេទសញ្ញាបត្រឧត្តមសិក្សាកម្រិតខ្ពស់បំផុត ដែលត្រូវបានប្រគល់ជូនទៅបុគ្គលណាម្នាក់ ដែលបានសិក្សាមុខជំនាញ ដូចជា វេជ្ជសាស្ត្រ ទន្តវេទនសាស្ត្រ ឱសថសាស្ត្រ វិស្វកម្ម អប់រំ ធុរកិច្ច និងវិចិត្រសិល្បៈ ជាដើម។ បុគ្គលទទួលសញ្ញាបត្រប្រភេទនេះ បំពេញកិច្ចការជាក់ស្តែងជាចម្បង និងបានចងក្រងចំណេះដឹង ដែលបានពីការសិក្សានិងបទពិសោធការងារទៅតាមវិធីសាស្ត្រ។ បុគ្គលទទួលសញ្ញាបត្របណ្ឌិតប្រភេទនេះ មានបំណងជាចម្បងគឺការបង្កើនសមត្ថភាពវិជ្ជាជីវៈផ្ទាល់ខ្លួន ឲ្យកាន់តែប្រសើរឡើង។ ចំពោះគោរម្យងារជាព្រឹទ្ធាចារ្យសិល្បៈ មានកម្រិតសមមូលនឹងសញ្ញាបត្របណ្ឌិតវិជ្ជាជីវៈ។

- សញ្ញាបត្របណ្ឌិតកិត្តិយស ជាសញ្ញាបត្របណ្ឌិតដែលគ្រឹះស្ថានឧត្តមសិក្សា ប្រគល់ជូនបុគ្គលណាម្នាក់ ដោយសារការទទួលស្គាល់ស្នាដៃឆ្នើមកម្រិតខ្ពស់ ដែលមានអត្ថប្រយោជន៍ដល់សង្គម និងមនុស្សជាតិ តាមរយៈសមិទ្ធផលការងារ ការសរសេរសៀវភៅ ឬការផ្សព្វផ្សាយការស្រាវជ្រាវជាដើម។

ជំពូកទី៣
លក្ខខណ្ឌសម្រាប់ការបណ្តុះបណ្តាលថ្នាក់បណ្ឌិតស្រាវជ្រាវ និង បណ្ឌិតវិជ្ជាជីវៈ

ផ្នែកទី១
លក្ខខណ្ឌសម្រាប់បើកការបណ្តុះបណ្តាលថ្នាក់បណ្ឌិត

មាត្រា ៥.-

គ្រឹះស្ថានឧត្តមសិក្សា ដែលបើកវគ្គបណ្តុះបណ្តាលថ្នាក់បណ្ឌិត ត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម៖

៥.១- អង្គភាពទទួលខុសត្រូវ

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានរចនាសម្ព័ន្ធគ្រប់គ្រង ថ្នាក់បណ្ឌិតមួយច្បាស់លាស់ ស្របនឹងផែនការអភិវឌ្ឍ នៃគ្រឹះស្ថានរបស់ខ្លួន
- អង្គភាពគ្រប់គ្រងថ្នាក់បណ្ឌិត ត្រូវកំណត់អំពីតួនាទី និងភារកិច្ចច្បាស់លាស់ ដើម្បីសម្របសម្រួលតាមកម្មវិធីថ្នាក់បណ្ឌិត
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានអង្គភាពគ្រប់គ្រង ដំណើរការស្រាវជ្រាវរបស់និស្សិត។

៥.២- មន្ត្រីទទួលខុសត្រូវ

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានមន្ត្រីដោយឡែក ទទួលបន្ទុកការបណ្តុះបណ្តាលថ្នាក់បណ្ឌិត
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវកំណត់អំពីតួនាទី និងភារកិច្ចរបស់មន្ត្រីម្នាក់ៗ ដែលទទួលបន្ទុកការបណ្តុះបណ្តាលថ្នាក់បណ្ឌិត ឲ្យបានច្បាស់លាស់
- ប្រធានអង្គភាពគ្រប់គ្រងថ្នាក់បណ្ឌិត (ឬព្រឹទ្ធបុរសទទួលបន្ទុកថ្នាក់ក្រោយបរិញ្ញាបត្រ) ត្រូវមានសញ្ញាបត្របណ្ឌិត។

៥.៣- ការរៀបចំលិខិតូបករណ៍

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានឯកសារបោះពុម្ពផ្សាយជាផ្លូវការ និងជាសាធារណៈ អំពីនីតិវិធីរដ្ឋបាលសំខាន់ៗ ដែលទាក់ទងនឹងការសិក្សានៅថ្នាក់បណ្ឌិត និងលិខិតបទដ្ឋានដទៃទៀត ចាប់ពីការដាក់ពាក្យចូលសិក្សា រហូតដល់ការបញ្ចប់ការសិក្សា។ ការរៀបរាប់នៅក្នុងលិខិតបទដ្ឋានទាំងនេះ ត្រូវមានភាពច្បាស់លាស់ ងាយយល់ សម្រាប់និស្សិតនិងសាស្ត្រាចារ្យ និងត្រូវមានការផ្សព្វផ្សាយតាមគេហទំព័រ របស់គ្រឹះស្ថានឧត្តមសិក្សា និងមានការបោះពុម្ពផ្សាយយ៉ាងទូលំទូលាយ
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវធ្វើការកំណត់ឲ្យបានច្បាស់លាស់ អំពីភាពខុសគ្នារវាងនិស្សិតពេញម៉ោង និងនិស្សិតមិនពេញម៉ោង និងត្រូវមានកាលវិភាគច្បាស់លាស់ សម្រាប់ការបញ្ចប់របស់និស្សិតប្រភេទនីមួយៗ
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវធ្វើការណែនាំច្បាស់លាស់ អំពីរយៈពេលអប្បបរមា និងអតិបរមានៃការសិក្សាថ្នាក់បណ្ឌិត និងអំពីការទទួលចុះឈ្មោះឡើងវិញរាល់ដើមឆ្នាំសិក្សា ក្នុងកម្មវិធីថ្នាក់បណ្ឌិត

- ការបញ្ចប់ការសិក្សា ដែលហួសពេលកំណត់អតិបរមា ដោយសារមូលហេតុនានា អាចអនុញ្ញាតឲ្យ ចំពោះតែនិស្សិត ដែលបានដាក់ពាក្យសុំជាផ្លូវការ និងមានការឯកភាពពីសាស្ត្រាចារ្យណែនាំប៉ុណ្ណោះ
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានលិខិតបទដ្ឋានច្បាស់លាស់ អំពីនីតិវិធីជាលាយលក្ខណ៍អក្សរ ដែល បង្ហាញអំពីដំណាក់កាលនីមួយៗ នៃកម្មវិធីថ្នាក់បណ្ឌិតសម្រាប់សាស្ត្រាចារ្យនិងនិស្សិត
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានឯកសារលម្អិតច្បាស់លាស់អំពីក្រមប្រតិបត្តិ និងគោលការណ៍ណែនាំ ដែលជានាតម្លាភាពពាក់ព័ន្ធនឹងភារកិច្ច របស់គ្រប់ភាគីនៅក្នុងកម្មវិធីថ្នាក់បណ្ឌិត រួមមាន និស្សិត ថ្នាក់បណ្ឌិតសាស្ត្រាចារ្យណែនាំ មន្ត្រីរដ្ឋបាល និងអ្នកពិនិត្យវាយតម្លៃលើនិក្ខេបបទ។ ចំណុច សំខាន់ៗ ដែលត្រូវបញ្ចូលមានដូចជា៖
    - ក. ជីវិតស្រាវជ្រាវនិងសិក្សា។
    - ខ. ការកំណត់អំពីភាពត្រឹមត្រូវជាម្ចាស់ ក្នុងស្នាដៃនិពន្ធតែម្នាក់ឯង ឬក្នុងស្នាដៃនិពន្ធរួមគ្នា ដែលត្រូវបានបោះពុម្ពផ្សាយ និងការថ្លែងអំណរគុណ ចំពោះអ្នកដែលបានរួមវិភាគទាន។
    - គ. បញ្ហាដែលទាក់ទងនឹងក្រមសីលធម៌និងកម្មសិទ្ធិបញ្ញា។
- គ្រឹះស្ថានឧត្តមសិក្សា អាចចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការ ជាមួយនឹងគ្រឹះស្ថានឧត្តមសិក្សានៅ ក្នុង និងនៅក្រៅប្រទេស ព្រមទាំងជាមួយអង្គការ សហគ្រាសជាតិនិងអន្តរជាតិ ដើម្បីបង្កភាពងាយ ស្រួល ដល់ការទទួលស្គាល់សញ្ញាបត្របណ្ឌិត និងការអភិវឌ្ឍវិទ្យាសាស្ត្រ
- មុននឹងចាប់ផ្តើមការបណ្តុះបណ្តាល គ្រឹះស្ថានឧត្តមសិក្សា ត្រូវបំពេញបែបបទលើកិច្ចព្រមព្រៀង និក្ខេបបទ ដែលត្រូវចុះហត្ថលេខា ដោយនិស្សិត សាស្ត្រាចារ្យណែនាំ និងគណៈគ្រប់គ្រងគ្រឹះស្ថាន បណ្តុះបណ្តាល។ ក្នុងពេលរៀបចំនិក្ខេបបទ និស្សិតត្រូវបានបញ្ចូលទៅក្នុងអង្គភាពស្រាវជ្រាវ នៃ គ្រឹះស្ថានបណ្តុះបណ្តាលរបស់ខ្លួន
- មុននឹងចាប់ផ្តើមការបណ្តុះបណ្តាលថ្នាក់បណ្ឌិត គ្រឹះស្ថានឧត្តមសិក្សា ត្រូវធានាថា លក្ខខណ្ឌ វិទ្យាសាស្ត្រ សម្ភារៈ និងហិរញ្ញវត្ថុ ត្រូវបានត្រៀមជាស្រេច ដើម្បីធានាដំណើរការល្អនៃការបណ្តុះ បណ្តាល។

មាត្រា ៦.-

លក្ខខណ្ឌសម្រាប់សាស្ត្រាចារ្យ មានដូចខាងក្រោម៖

៦.១- ប្រភេទសាស្ត្រាចារ្យណែនាំ

- សាស្ត្រាចារ្យណែនាំនិស្សិតមានពីរប្រភេទគឺ សាស្ត្រាចារ្យណែនាំគោល និងសាស្ត្រាចារ្យណែនាំរង ឬសហសាស្ត្រាចារ្យណែនាំ
- សាស្ត្រាចារ្យណែនាំគោល គឺជាសាស្ត្រាចារ្យណែនាំទីមួយ និងជាបុគ្គលិកសិក្សា ដែលមានសញ្ញាបត្រ បណ្ឌិតលើមុខវិជ្ជាសមស្រប ជាមួយនឹងប្រធានបទស្រាវជ្រាវរបស់និស្សិត និងមានបទពិសោធ ស្រាវជ្រាវ ឬការបង្រៀនច្បាស់លាស់។ សាស្ត្រាចារ្យណែនាំគោល ត្រូវជាសាស្ត្រាចារ្យពេញម៉ោង របស់គ្រឹះស្ថានឧត្តមសិក្សាផ្ទាល់ និងជាបញ្ញវន្តដែលសកម្ម និងមានជោគជ័យក្នុងជំនាញរបស់ខ្លួន
- សាស្ត្រាចារ្យណែនាំរង ឬសហសាស្ត្រាចារ្យណែនាំ គឺជាសាស្ត្រាចារ្យ ឬអ្នកជំនាញ ដែលសហការ ណែនាំ ជាមួយនឹងសាស្ត្រាចារ្យណែនាំគោល និងដែលមានសញ្ញាបត្របណ្ឌិតលើមុខវិជ្ជាសមស្រប ជាមួយនឹងប្រធានបទស្រាវជ្រាវរបស់និស្សិត និងមានបទពិសោធស្រាវជ្រាវឬបង្រៀនសមស្រប។

៦.២- ការបណ្តុះបណ្តាលនិងការជួយគាំទ្រនិស្សិត

- និស្សិតថ្នាក់បណ្ឌិតម្នាក់ៗ មានសាស្ត្រាចារ្យណែនាំគោលម្នាក់
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវកំណត់លក្ខខណ្ឌច្បាស់លាស់ អំពីនិរន្តរភាពរបស់សាស្ត្រាចារ្យណែនាំគោលក្នុងការណែនាំនិស្សិតម្នាក់ៗ
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមាននីតិវិធីច្បាស់លាស់ ដើម្បីកំណត់សមត្ថភាពនិងលទ្ធភាពរបស់សាស្ត្រាចារ្យម្នាក់ៗ ក្នុងការទទួលយកនិស្សិតមកណែនាំ។ នីតិវិធីទាំងនេះ ត្រូវរាប់បញ្ចូលនូវបទពិសោធ កេរ្តិ៍ឈ្មោះ និងជោគជ័យរបស់សាស្ត្រាចារ្យ និងក្រុមរបស់សាស្ត្រាចារ្យនោះ ក្នុងការណែនាំនិស្សិតថ្នាក់បណ្ឌិត និងក្នុងការស្រាវជ្រាវនានា
- ចំនួននិស្សិតដែលសាស្ត្រាចារ្យណែនាំគោលម្នាក់ៗ អាចណែនាំបាន មានការប្រែប្រួលតាមជំនាញ។ ក្នុងគ្រប់ករណី សាស្ត្រាចារ្យម្នាក់មិនអាចមាននិស្សិតក្នុងបន្ទុកណែនាំ នៅថ្នាក់បណ្ឌិតលើសពី ៩(ប្រាំបួន)រូបឡើយ
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានគោលការណ៍អំពីការលាឈប់ ឬការចូលនិវត្តន៍របស់សាស្ត្រាចារ្យណែនាំ។ ត្រូវមានសាស្ត្រាចារ្យណែនាំស្តីទីទទួលខុសត្រូវបន្តជាបន្ទាន់ នៅពេលដែលសាស្ត្រាចារ្យណែនាំគោលលាឈប់ ឬចូលនិវត្តន៍។

៦.៣- ភារកិច្ចនិងការទទួលខុសត្រូវរបស់សាស្ត្រាចារ្យ

- សាស្ត្រាចារ្យណែនាំមានភារកិច្ច ជួយនិស្សិតឲ្យបញ្ចប់ការស្រាវជ្រាវ របស់ខ្លួនតាមកាលកំណត់។ ភារកិច្ចសំខាន់ៗរួមមាន ៖
  - ក- ណែនាំដល់និស្សិតអំពីការរៀបចំគម្រោងពេលវេលានៃការស្រាវជ្រាវ។
  - ខ- ផ្តល់ដល់និស្សិតនូវការណែនាំផ្នែកវិទ្យាសាស្ត្រ។
  - គ- ធ្វើការវាយតម្លៃលើការរីកចម្រើននៃការស្រាវជ្រាវ។
  - ឃ- ជួយសម្របសម្រួលផ្នែករដ្ឋបាល។
  - ង- ណែនាំអំពីវិធីសាស្ត្រឧបករណ៍ និងសម្ភារៈនានាទាក់ទងនឹងការស្រាវជ្រាវរបស់និស្សិត។
  - ច- ផ្តល់ការណែនាំដល់និស្សិត ដើម្បីមានទំនាក់ទំនងទូលំទូលាយ ជាមួយនឹងអ្នកជំនាញនានា។
  - ឆ- លើកទឹកចិត្តនិស្សិតឲ្យចូលរួមក្នុងសកម្មភាពសិក្សានិងស្រាវជ្រាវ។
- គ្រប់សាស្ត្រាចារ្យណែនាំគោលនិងសាស្ត្រាចារ្យណែនាំរងឬសហសាស្ត្រាចារ្យណែនាំ ត្រូវយល់អំពី៖
  - ក- ភារកិច្ចនិងសិទ្ធិរបស់ខ្លួនជាសាស្ត្រាចារ្យចំពោះនិស្សិតថ្នាក់បណ្ឌិតដែលខ្លួនណែនាំ។
  - ខ- ភារកិច្ចនិងសិទ្ធិរបស់និស្សិតថ្នាក់បណ្ឌិត ក្រោមការណែនាំរបស់ខ្លួន។
  - គ- បញ្ញត្តិទាំងឡាយស្តីពីកម្មវិធីវគ្គបណ្ឌិតនិងការពិនិត្យវាយតម្លៃលើថ្នាក់បណ្ឌិត។
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវកំណត់អំពីលក្ខខណ្ឌ ដែលតម្រូវឲ្យមានសហសាស្ត្រាចារ្យណែនាំ
- ក្នុងករណីដែលសាស្ត្រាចារ្យណែនាំ ឬនិស្សិត អវត្តមានក្នុងរយៈពេលវែង ដោយមូលហេតុណាមួយ គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានការកំណត់ច្បាស់លាស់ អំពីការរក្សាផលប្រយោជន៍របស់សាស្ត្រាចារ្យណែនាំនិងនិស្សិត
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានការកំណត់ច្បាស់លាស់អំពីនីតិវិធី នៃការផ្លាស់ប្តូរសាស្ត្រាចារ្យណែនាំគោល ឬសហសាស្ត្រាចារ្យណែនាំ

- តាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ គ្រឹះស្ថានឧត្តមសិក្សាបរទេសជាដៃគូ អាចផ្តល់សាស្ត្រាចារ្យណែនាំរបស់ខ្លួន ឲ្យបំពេញភារកិច្ចជាសហសាស្ត្រាចារ្យណែនាំ
- តាមរយៈកិច្ចព្រមព្រៀង អង្គការ ឬសហគ្រាសជាដៃគូ អាចផ្តល់អ្នកជំនាញដែលមានគ្រប់លក្ខណៈវិនិច្ឆ័យ សម្រាប់ការណែនាំឲ្យចូលរួមបំពេញភារកិច្ច ជាសហសាស្ត្រាចារ្យណែនាំ
- ក្រុមប្រឹក្សាវិទ្យាសាស្ត្រនៃគ្រឹះស្ថានបណ្តុះបណ្តាល ត្រូវចូលរួមក្នុងការកំណត់អំពីលក្ខខណ្ឌ និងការរៀបចំនីតិវិធីខាងលើ។

មាត្រា ៧.-

លក្ខខណ្ឌសម្រាប់និស្សិត មានដូចខាងក្រោម៖

៧.១- ការជ្រើសរើសនិស្សិត

- ចំនួននិស្សិតដែលត្រូវជ្រើសរើស ត្រូវសមស្របជាមួយនឹងធនធាន របស់គ្រឹះស្ថានឧត្តមសិក្សា
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវកំណត់ឲ្យបានច្បាស់លាស់អំពីលក្ខខណ្ឌ នៃការជ្រើសរើសនិស្សិតចូលសិក្សាវគ្គបណ្ឌិត។ លក្ខខណ្ឌជាមូលដ្ឋាននៃការជ្រើសរើសនិស្សិតមានដូចជា៖
  ក- ការឆ្លងកាត់ការសិក្សាគ្រប់ភូមិសិក្សា ដែលមានលក្ខណៈជាប្រព័ន្ធ និងប្រក្រតី។
  ខ- ពិន្ទុខ្ពស់ក្នុងកម្រិតសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។
  គ- សមត្ថភាពក្នុងការស្រាវជ្រាវ។
  ឃ- ចំណេះដឹងភាសាបរទេស។
  ង- ពិន្ទុនៃការប្រឡងចូល និងសេចក្តីស្នើគម្រោងស្រាវជ្រាវរបស់និស្សិត។
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវរិះរកលទ្ធភាពក្នុងការផ្តល់ការសិក្សាថ្នាក់បណ្ឌិត ឲ្យនិស្សិតបរទេសអាចមានឱកាសបានចូលសិក្សាផងដែរ។ សាស្ត្រាចារ្យណែនាំនិស្សិតបរទេស ត្រូវបានលើកទឹកចិត្ត និងទទួលការគាំទ្រ។

៧.២- ភារកិច្ចនិងការទទួលខុសត្រូវ

ការបញ្ចប់ការសិក្សាវគ្គបណ្ឌិតដោយជោគជ័យ តម្រូវឲ្យមានការអភិវឌ្ឍសមត្ថភាពជំនាញនិងទំនុកចិត្តលើខ្លួនឯង។ និស្សិតទាំងអស់ត្រូវមានភារកិច្ចនិងការទទួលខុសត្រូវលើការស្រាវជ្រាវ ដោយឯករាជ្យ ក្រោមការដឹកនាំរបស់សាស្ត្រាចារ្យណែនាំ សំដៅអភិវឌ្ឍបញ្ញាញាណផ្ទាល់ខ្លួន។ ភារកិច្ចនិងការទទួលខុសត្រូវទាំងនោះមានដូចជា៖

ក- ការលើកផែនការនិងធ្វើការស្រាវជ្រាវយ៉ាងសកម្ម។
ខ- ការកំណត់និងដោះស្រាយបញ្ហាក្នុងការស្រាវជ្រាវ។
គ- ការឆ្លើយតបតាមតម្រូវការរដ្ឋបាលរបស់គ្រឹះស្ថានឧត្តមសិក្សា។
ឃ- ការគោរពក្រមសីលធម៌ជាអ្នកស្រាវជ្រាវ។
ង- ការបោះពុម្ពស្នាដៃស្រាវជ្រាវក្នុងទស្សនាវដ្តី ឬវេទិកា ដែលមានលក្ខណៈវិទ្យាសាស្ត្រ ឬវិជ្ជាជីវៈ។
ច- ការទទួលខុសត្រូវលើនិក្ខេបបទចុងក្រោយរបស់ខ្លួន។
ឆ- ការចូលរួមយ៉ាងសកម្មក្នុងជីវភាពសិក្សានៃគ្រឹះស្ថានឧត្តមសិក្សា។

ផ្នែកទី២
លក្ខខណ្ឌសម្រាប់ដំណើរការការបណ្ដុះបណ្ដាលថ្នាក់បណ្ឌិត

មាត្រា ៨.-

លក្ខខណ្ឌនៃការបណ្ដុះបណ្ដាល មានដូចខាងក្រោម៖

៨.១- ចរិតនៃការបណ្ដុះបណ្ដាល

- គ្រឹះស្ថានឧត្ដមសិក្សា ត្រូវកំណត់គោលការណ៍ ក្នុងការបណ្ដុះបណ្ដាលឲ្យបានច្បាស់លាស់
- គ្រឹះស្ថានឧត្ដមសិក្សា ត្រូវរៀបចំកម្មវិធីសិក្សាថ្នាក់បណ្ឌិត ឲ្យមានសមាសភាគនៃចំណេះដឹងកម្រិតខ្ពស់។ សមាសភាគនេះមានដូចជា៖
  - ក- ការសិក្សាវិធីសាស្ត្រស្រាវជ្រាវ និងវិធីសាស្ត្រនានា នៃការវិភាគទិន្នន័យ។
  - ខ- ការសិក្សាដែលផ្ដល់ចំណេះដឹងខ្ពស់ពាក់ព័ន្ធនឹងទ្រឹស្ដី និងការអនុវត្តវិជ្ជាជីវៈ សក្ដិសមនឹងជំនាញ និងកម្រិតសញ្ញាបត្រ។
  - គ- សកម្មភាពរៀបចំឡើង ដើម្បីពង្រីកចំណេះដឹងរបស់និស្សិត ក្នុងការស្រាវជ្រាវស្របតាមជំនាញ។
- គ្រឹះស្ថានឧត្ដមសិក្សា ត្រូវបង្កើតលក្ខណវិនិច្ឆ័យលើលទ្ធផល នៃការស្រាវជ្រាវនិងអត្ថបទបោះពុម្ព និងបង្កើតគោលការណ៍ នៃការផ្សព្វផ្សាយលទ្ធផល នៃការស្រាវជ្រាវនិងអត្ថបទបោះពុម្ព។ លក្ខណវិនិច្ឆ័យ និងគោលការណ៍នេះ ត្រូវផ្សព្វផ្សាយឲ្យបានទូលំទូលាយ ដល់និស្សិតនិងសាស្ត្រាចារ្យ
- ការបណ្ដុះបណ្ដាលថ្នាក់បណ្ឌិតស្រាវជ្រាវ ត្រូវសង្កត់ធ្ងន់ទាំងលើលទ្ធផលនៃការស្រាវជ្រាវ ដែលខុសប្លែកពីការបណ្ដុះបណ្ដាលថ្នាក់បណ្ឌិតវិជ្ជាជីវៈ ដែលសង្កត់ធ្ងន់លើលទ្ធផល នៃការសិក្សាទាំងលើការស្រាវជ្រាវ។

៨.២- រចនាសម្ព័ន្ធនិងរយៈពេលនៃការបណ្ដុះបណ្ដាល

- គ្រឹះស្ថានឧត្ដមសិក្សា ត្រូវមានសេចក្ដីប្រកាសច្បាស់លាស់ អំពីរយៈពេលសិក្សាស្រាវជ្រាវ នៃថ្នាក់បណ្ឌិត។ ថ្នាក់បណ្ឌិតមានរយៈពេលពី៣(បី)ទៅ៦(ប្រាំមួយ)ឆ្នាំ សម្រាប់ថ្នាក់ បណ្ឌិតពេញម៉ោង និងហួតដល់៨(ប្រាំបី)ឆ្នាំ សម្រាប់ថ្នាក់បណ្ឌិតមិនពេញម៉ោង
- ក្នុងករណីពិសេស សម្រាប់ថ្នាក់បណ្ឌិតវិជ្ជាជីវៈ តាមសំណើរបស់ស្ថាប័នជំនាញដែលជាស្ថាប័នសាមីដោយមានការឯកភាព ពីក្រសួងទទួលបន្ទុកវិស័យអប់រំ គ្រឹះស្ថានឧត្ដមសិក្សា អាចធ្វើការវាយតម្លៃលើលទ្ធផលស្នាដៃឆ្នើមរបស់បេក្ខជន។ មុននឹងទទួលសញ្ញាបត្របណ្ឌិតវិជ្ជាជីវៈ បេក្ខជនប្រភេទនោះ ត្រូវចងក្រងលទ្ធផលស្រាវជ្រាវរបស់ខ្លួនជានិក្ខេបបទ និងដាក់ជូនគ្រឹះស្ថានឧត្ដមសិក្សា ដើម្បីប្រគល់ជូនអ្នកពិនិត្យវាយតម្លៃ និងធ្វើការការពារនៅចំពោះមុខគណៈកម្មការការពារនិក្ខេបបទ
- ការសិក្សាថ្នាក់បណ្ឌិតចែកចេញជាបីដំណាក់កាល៖
  - ក-ដំណាក់កាលទី១ គឺការសិក្សានិងការកែលម្អបញ្ចប់ និងការការពារគម្រោងស្នើស្រាវជ្រាវ។ និស្សិតត្រូវប្រឡងបញ្ចប់ការសិក្សាកម្រិតអប្បបរមា (ទាំងមុខជំនាញទាំងភាសាបរទេស) ដោយជោគជ័យ ទើបអាចបន្តទៅដំណាក់កាលទី២បាន។
  - ខ-ដំណាក់កាលទី២ គឺការស្រាវជ្រាវ (និងការសិក្សាបន្ត សម្រាប់ថ្នាក់បណ្ឌិតវិជ្ជាជីវៈ) ការបោះពុម្ពផ្សាយលទ្ធផលនៃការស្រាវជ្រាវ និងការរៀបចំនិក្ខេបបទ។

គ-ដំណាក់កាលទី៣ គឺការសរសេរបញ្ចប់និក្ខេបបទ និងការការពារនិក្ខេបបទ។

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវរៀបចំឲ្យនិស្សិតធ្វើបទបង្ហាញ និងការការពារយ៉ាងតិចពីរដំណាក់កាល មុននឹងមានការការពារបញ្ចប់។ បទបង្ហាញនិងការការពារទាំងពីរដំណាក់កាលនោះគឺ

ក-បទបង្ហាញនិងការការពារគម្រោងស្រាវជ្រាវ (ការការពារគម្រោង)។

ខ-បទបង្ហាញនិងការការពារលទ្ធផលស្រាវជ្រាវបឋម (ការបង្ហាញអំពីការរីកចម្រើននៃការស្រាវជ្រាវ)។

៨.៣- គណៈកម្មការនិងក្រុមទទួលបន្ទុកការបណ្តុះបណ្តាល

គណៈកម្មការនិងក្រុមសាស្ត្រាចារ្យ ឬអ្នកជំនាញមានបួនប្រភេទ ក្នុងដំណើរការបណ្តុះបណ្តាលថ្នាក់បណ្ឌិត។ គណៈកម្មការនិងក្រុមទាំងបួននោះគឺ៖

- គណៈកម្មការទទួលខុសត្រូវថ្នាក់បណ្ឌិត ដែលជាក្រុមសាស្ត្រាចារ្យ និងថ្នាក់ដឹកនាំ នៅក្នុងគ្រឹះស្ថានឧត្តមសិក្សា ដែលត្រូវបានបង្កើតឡើងដោយគ្រឹះស្ថានឧត្តមសិក្សា ដើម្បីលើកគោលការណ៍ និងត្រួតពិនិត្យទូទៅលើថ្នាក់បណ្ឌិត
- ក្រុមសាស្ត្រាចារ្យណែនាំនិស្សិតថ្នាក់បណ្ឌិត ដែលត្រូវបានបង្កើតឡើងដោយគ្រឹះស្ថានឧត្តមសិក្សា និងមានសមាជិកជាសាស្ត្រាចារ្យ និង/ឬជាបុគ្គលដែលមានសមត្ថភាព ដូចមានចែងក្នុងអនុក្រឹត្យនេះដើម្បីណែនាំកិច្ចការសិក្សានិងស្រាវជ្រាវរបស់និស្សិតម្នាក់ៗ
- ក្រុមអ្នកពិនិត្យវាយតម្លៃលើនិក្ខេបបទ។ ក្រុមនេះ គឺជាក្រុមអ្នកជំនាញ ដែលមានភារកិច្ចពិនិត្យវាយតម្លៃលើនិក្ខេបបទ មុនពេលនិក្ខេបបទត្រូវបានការពារបញ្ចប់។ សមាជិកនៃក្រុមនេះមាននៅក្នុងនិងនៅក្រៅគ្រឹះស្ថានឧត្តមសិក្សា។ ក្រសួងទទួលបន្ទុកវិស័យអប់រំមានភារកិច្ចរៀបចំបញ្ជីឈ្មោះក្រុមសាស្ត្រាចារ្យនិងអ្នកជំនាញ ដើម្បីសម្រួលដល់គ្រឹះស្ថានឧត្តមសិក្សាក្នុងការជ្រើសរើសអ្នកពិនិត្យនិងវាយតម្លៃមកពីខាងក្រៅគ្រឹះស្ថានឧត្តមសិក្សា
- គណៈកម្មការការពារនិក្ខេបបទបញ្ចប់ ត្រូវបានរៀបចំឡើងដោយគ្រឹះស្ថានឧត្តមសិក្សា និងមានការឯកភាពពីក្រសួងទទួលបន្ទុកវិស័យអប់រំ។ ចំនួនសមាជិកនៃគណៈកម្មការនេះមានចែងក្នុងផ្នែកទីបីនៃអនុក្រឹត្យនេះ។ សមាជិកនៃគណៈកម្មការនេះមានមកពីថ្នាក់ដឹកនាំគ្រឹះស្ថានឧត្តមសិក្សាសាស្ត្រាចារ្យណែនាំ អ្នកពិនិត្យវាយតម្លៃលើនិក្ខេបបទ តំណាងក្រសួងទទួលបន្ទុកវិស័យអប់រំ និងអង្គភាពដទៃទៀតក្នុងករណីចាំបាច់។

៨.៤- បរិយាកាសនៃការបណ្តុះបណ្តាល

- គ្រឹះស្ថានឧត្តមសិក្សា អាចមានកិច្ចសហប្រតិបត្តិការ ជាមួយនឹងគ្រឹះស្ថានឧត្តមសិក្សា ក្នុងប្រទេស និងក្រៅប្រទេស ដើម្បីពង្រីកឱកាសសម្រាប់និស្សិតថ្នាក់បណ្ឌិត ក្នុងការទទួលយកជំនាញពីគ្រឹះស្ថានឧត្តមសិក្សាដៃគូ ក៏ដូចជាពីសាស្ត្រាចារ្យបរទេស
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានការណែនាំអំពីកម្រិតអប្បបរមា នៃការពិភាក្សាពិគ្រោះយោបល់រវាងនិស្សិត និងសាស្ត្រាចារ្យណែនាំ និងត្រូវមានជម្រើសសមរម្យនៅពេលដែលកម្រិតនៃការជួបពិភាក្សានេះ មិនអាចធ្វើទៅកើតដោយសារមូលហេតុណាមួយ
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានយន្តការដោយឡែក សម្រាប់និស្សិតដែលគម្រោងស្រាវជ្រាវមានលក្ខណៈពិសេសដោយឡែក និងត្រូវមានការផ្តល់ជូន នូវការគាំទ្រមួយសមស្រប ដល់គម្រោងស្រាវជ្រាវបែបនេះ

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវបោះពុម្ពផ្សាយប្រចាំឆ្នាំ នូវបញ្ជីឈ្មោះនិស្សិតថ្នាក់បណ្ឌិត ប្រធានបទនិក្ខេបបទ និងឈ្មោះសាស្ត្រាចារ្យណែនាំ ដើម្បីជំរុញឲ្យមានទំនាក់ទំនងគ្នាកាន់តែប្រសើរ រវាងនិស្សិតថ្នាក់បណ្ឌិត និងអ្នកស្រាវជ្រាវឯទៀត
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានគោលការណ៍ណែនាំអំពីសម្ភារៈនានា ដែលប្រើប្រាស់ដោយនិស្សិតថ្នាក់បណ្ឌិត រួមទាំងលក្ខណៈពិសេសនៃការប្រើប្រាស់បណ្ណាល័យ ការខ្ចីសៀវភៅឆ្លងបណ្ណាល័យ និងសិទ្ធិប្រើប្រាស់សម្ភារៈមួយចំនួន របស់បុគ្គលិកនៃគ្រឹះស្ថានឧត្តមសិក្សា។

មាត្រា ៩.-

លក្ខខណ្ឌដែលពាក់ព័ន្ធនឹងប្រធានបទនិក្ខេបបទ មានដូចខាងក្រោម៖

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងនិស្សិត និងប្រធានបទស្រាវជ្រាវរបស់និស្សិត
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានក្រមសីលធម៌សម្រាប់ការស្រាវជ្រាវក្នុងវិស័យនីមួយៗ និងមានយន្តការសម្រាប់ធានាថាប្រធានបទនៃការស្រាវជ្រាវមានផលប្រយោជន៍ដល់សង្គម និងស្របតាមតម្រូវការរបស់ប្រទេស និងមនុស្សជាតិ។
- និស្សិតនិងសាស្ត្រាចារ្យណែនាំ ត្រូវមានការយល់ដឹងអំពីគោលនយោបាយរបស់គ្រឹះស្ថានឧត្តមសិក្សាលើកម្មសិទ្ធិបញ្ញា។ គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ត្រូវបានផ្តល់ព័ត៌មានអំពីបញ្ហាទាក់ទងនឹងកម្មសិទ្ធិបញ្ញានៅពេលដែលបញ្ហានេះបានលេចឡើងដោយមូលហេតុណាមួយ។

មាត្រា ១០.-

គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានក្រមប្រតិបត្តិស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់និស្សិតថ្នាក់បណ្ឌិត សាស្ត្រាចារ្យណែនាំ និងគ្រឹះស្ថានឧត្តមសិក្សាផ្ទាល់។ ក្រមប្រតិបត្តិនេះ ត្រូវបានចែកជូនដល់គ្រប់ភាគីពាក់ព័ន្ធ។

មាត្រា ១១.-

ការបោះពុម្ពនិងការចូលរួមសិក្ខាសាលា មានដូចខាងក្រោម៖

- និស្សិតថ្នាក់បណ្ឌិត ត្រូវមានបទបង្ហាញអំពីលទ្ធផលស្រាវជ្រាវរបស់ខ្លួននៅក្នុងសិក្ខាសាលាឬសន្និសីទជាតិ ឬអន្តរជាតិ
- មុនពេលប្រគល់និក្ខេបបទដើម្បីការពារជាចុងក្រោយ និស្សិត ត្រូវមានអត្ថបទបោះពុម្ពផ្សាយជាសាធារណៈដែលទាក់ទងនឹងប្រធានបទនិក្ខេបបទយ៉ាងតិចមួយអត្ថបទ នៅក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រ ឬទស្សនាវដ្តីបោះពុម្ពដោយសមាគមវិជ្ជាជីវៈ។

មាត្រា ១២.-

ការត្រួតពិនិត្យកម្មវិធីថ្នាក់បណ្ឌិត មានដូចខាងក្រោម៖

១២.១- ការត្រួតពិនិត្យ

- គ្រឹះស្ថានឧត្តមសិក្សា ដែលមានវគ្គបណ្ឌិត ត្រូវមាននីតិវិធីដើម្បីធានាស្តង់ដាគុណភាព នៃកម្មវិធីថ្នាក់បណ្ឌិត ដែលមានជាអាទិ៍៖

  ក- ការពិនិត្យឡើងវិញតាមកាលកំណត់លើផ្នែកនីមួយៗនៃថ្នាក់បណ្ឌិត។

  ខ- ការអង្កេតតាមកាលកំណត់ ដើម្បីស្វែងយល់អំពីការពេញចិត្ត របស់និស្សិតថ្នាក់បណ្ឌិតលើកម្មវិធីថ្នាក់បណ្ឌិត។

  គ- ការអង្កេតលើការបញ្ចប់របស់និស្សិតថ្នាក់បណ្ឌិត។

ឃ- ការចងក្រងនិងការបោះពុម្ព នូវពេលវេលានិងអត្រានៃការបញ្ចប់ និងទិន្នន័យទូទៅដែលអាចឆ្លុះឲ្យឃើញអំពីការបំពេញភារកិច្ចរបស់ផ្នែកនីមួយៗនៃគ្រឹះស្ថានឧត្តមសិក្សា។

- ការត្រួតពិនិត្យរបស់គ្រឹះស្ថានឧត្តមសិក្សា មានដូចជា៖

ក- ការជួបប្រជុំគ្នាដំបូងរវាងនិស្សិតថ្នាក់បណ្ឌិតនិងក្រុមសាស្ត្រាចារ្យណែនាំ ដើម្បីកំណត់នីតិវិធីក្នុងការស្រាវជ្រាវឲ្យមានការឯកភាពគ្នា។ ក្នុងកិច្ចប្រជុំដំបូងនេះ គម្រោងស្រាវជ្រាវរបស់និស្សិតថ្នាក់បណ្ឌិត ត្រូវបានលើកយកមកពិភាក្សាលម្អិត។

ខ- ការកំណត់ឲ្យនិស្សិតរៀបចំផែនការ សម្រាប់ការស្រាវជ្រាវ និងការកំណត់ចន្លោះពេលពីដំណាក់កាលមួយ ទៅដំណាក់កាលមួយទៀត នៃការស្រាវជ្រាវ។

គ- ការវាយតម្លៃលើការវិវត្តទូទៅរបស់និស្សិត ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត។

ឃ-ការវាយតម្លៃជាទៀងទាត់ ដោយមានការកត់ត្រាជាលាយលក្ខណ៍អក្សរប្រកប ដោយតម្លាភាពក្នុងការវាយតម្លៃ ដើម្បីកំណត់ការរីកចម្រើននៃការស្រាវជ្រាវ។

ង- ការឯកភាពគ្នារបស់ក្រុមសាស្ត្រាចារ្យណែនាំ អំពីលទ្ធផលនៃការវាយតម្លៃលើការវិវត្ត នៃការស្រាវជ្រាវរបស់និស្សិតមុនពេលអនុញ្ញាត ឲ្យមានការបន្តការស្រាវជ្រាវតទៅទៀត។

១២.២- ការប្តឹងតវ៉ា

គ្រឹះស្ថានឧត្តមសិក្សា ត្រូវមាននីតិវិធីច្បាស់លាស់ ងាយយល់ ក្នុងការប្តឹងតវ៉ា។ និស្សិតម្នាក់ៗ អាចប្តឹងតវ៉ាពេលណាក៏បានអំពីបញ្ហា ដែលទាក់ទងនឹងគម្រោងស្រាវជ្រាវ និងសាស្ត្រាចារ្យណែនាំរបស់ខ្លួន។ យន្តការបណ្តឹងនេះផ្តើមចេញពីការតវ៉ា មិនផ្លូវការនៅគ្រាដំបូងៗ និងឈានទៅការប្តឹងតវ៉ាជាផ្លូវការនៅកាលៈទេសៈមួយដែលសមស្រប។ នីតិវិធីនៃការប្តឹងតវ៉ា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យអប់រំ។

មាត្រា ១៣.-

ចំណុចពាក់ព័ន្ធនឹងនិក្ខេបបទ មានដូចខាងក្រោម៖

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវបញ្ជាក់ច្បាស់លាស់នៅក្នុងការណែនាំរបស់ខ្លួនអំពីទម្រង់និងកត្តាជានាគុណភាពដទៃទៀតនៃនិក្ខេបបទ។ ទម្រង់និងកត្តាជានាគុណភាពនេះ អាចមានភាពខុសប្លែកគ្នាខ្លះៗ ទៅតាមជំនាញនីមួយៗ។ ជារួម និក្ខេបបទថ្នាក់បណ្ឌិតមួយសមមូលនឹងអត្ថបទ ដែលអាចបោះពុម្ពបាននៅក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រ យ៉ាងតិចចំនួន២(ពីរ)អត្ថបទ
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានសេវាហ័ស និងប្រកបដោយប្រសិទ្ធភាព ដើម្បីជួយនិស្សិតក្នុងការសរសេរនិក្ខេបបទ។ សេវាទាំងនេះមានដូចជា៖

ក- ផែនការការងារជាប្រព័ន្ធ រួមទាំងការពិគ្រោះយោបល់តាមកាលកំណត់ ជាមួយនឹងសាស្ត្រាចារ្យណែនាំគោល។

ខ- ការបណ្តុះបណ្តាលបន្ថែម អំពីការរៀបចំផែនការការងារ បែបបទនៃការសរសេរវិធីសាស្ត្រ និងការប្រើកុំព្យូទ័រ។

គ- ផ្តល់សម្ភារៈចាំបាច់ដើម្បីសរសេរនិក្ខេបបទ ដូចជាការប្រើប្រាស់កុំព្យូទ័ររបស់គ្រឹះស្ថានឧត្តមសិក្សា។

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវកំណត់ថ្ងៃចុងក្រោយ ក្នុងឆ្នាំសិក្សានីមួយៗ ក្នុងការទទួលនិក្ខេបបទ និងទុករយៈពេលសមស្របមួយ ដើម្បីឱ្យមានការពិនិត្យវាយតម្លៃ ការកែលម្អ និងការសរសេររបាយការណ៍របស់អ្នកពិនិត្យ និងវាយតម្លៃ

- និស្សិត អាចធ្វើការសម្រេចចិត្ត ក្នុងការសរសេរនិក្ខេបបទបញ្ចប់ និងការប្រគល់និក្ខេបបទ ទៅគ្រឹះស្ថានឧត្តមសិក្សា ដើម្បីស្នើសុំការធ្វើការការពារ ក្រោយពេលទទួលការណែនាំ ពីក្រុមសាស្ត្រាចារ្យណែនាំ
- និក្ខេបបទ ត្រូវយកទៅតម្កល់ទុកនៅបណ្ណសារដ្ឋានជាតិកម្ពុជា ក្រោយពេលការការពារបញ្ចប់ដោយជោគជ័យ។

ផ្នែកទី៣
លក្ខខណ្ឌសម្រាប់ការបញ្ចប់ការបណ្តុះបណ្តាលថ្នាក់បណ្ឌិត

មាត្រា ១៤.-

ការប្រឡងបញ្ចប់ការសិក្សា មានដូចខាងក្រោមៈ

១៤.១- លក្ខខណ្ឌទូទៅ

- និស្សិត ត្រូវបញ្ចប់ដោយជោគជ័យគ្រប់មុខវិជ្ជាសិក្សា គ្រប់ជំហាននៃដំណើរការបណ្តុះបណ្តាលមុនពេលប្រគល់និក្ខេបបទ សម្រាប់ការពិនិត្យ និងការវាយតម្លៃ
- ការចេញសញ្ញាបត្របណ្ឌិត ត្រូវផ្អែកលើគោលការណ៍នៃការវាយតម្លៃឯករាជ្យពីខាងក្រៅ ដោយគ្មានភាពលម្អៀង ទៅលើគុណភាពនៃស្នាដៃស្រាវជ្រាវ និងត្រូវធ្វើឡើងអាស្រ័យលើលទ្ធផល នៃការការពារជាចុងក្រោយ ដោយមិនគិតអំពីការសិក្សាមុន។
- បេក្ខជន ត្រូវទទួលបាននូវការពន្យល់អំពីបែបបទ នៃការប្រឡងបញ្ចប់ និងកាលបរិច្ឆេទនៃការប្រឡងបញ្ចប់មិនតិច ជាង៤(បួន)ខែមុន។

១៤.២- យន្តការត្រួតពិនិត្យវាយតម្លៃនិក្ខេបបទ និងរបាយការណ៍

- ការប្រឡងបញ្ចប់រួមមានការពិនិត្យវាយតម្លៃ របស់អ្នកជំនាញលើនិក្ខេបបទ ដោយអ្នកពិនិត្យវាយតម្លៃនិក្ខេបបទ៣(បី)រូប រួមនឹងការការពារដោយផ្ទាល់មាត់ពីបេក្ខជនបណ្ឌិត និងជាសាធារណៈនៅពេលការពារនិក្ខេបបទ
- គណៈមេប្រយោគជាអ្នកទទួលខុសត្រូវ លើការពិនិត្យរបាយការណ៍ទាំងអស់ និងវាយតម្លៃលើលទ្ធផលនៃដំណើរការប្រឡងជាទូទៅ។ គណៈមេប្រយោគមានសមាសភាពពី៥(ប្រាំ) ទៅ៧(ប្រាំពីរ) រូបដែល ក្នុងនោះមានទាំងអ្នកពិនិត្យវាយតម្លៃ៣(បី)រូបផងដែរ
- និក្ខេបបទត្រូវមានការពិនិត្យវាយតម្លៃពីសំណាក់អ្នកពិនិត្យវាយតម្លៃ៣(បី)រូប ដែលជាអ្នកមានសញ្ញាបត្របណ្ឌិត និងស្នាដៃឆ្នើមក្នុងវិស័យរបស់និក្ខេបបទ និងជាទូទៅមានបទពិសោធក្នុងការដឹកនាំការសរសេរនិក្ខេបបទ និងពិនិត្យវាយតម្លៃនិក្ខេបបទ។ ក្នុងចំណោមអ្នកពិនិត្យនិងវាយតម្លៃនិក្ខេបបទទាំងបីនាក់មាន២(ពីរ)រូបជាអ្នកខាងក្រៅ គ្រឹះស្ថានឧត្តមសិក្សា និង១(មួយ)រូបជាបុគ្គលិករបស់គ្រឹះស្ថានឧត្តមសិក្សា ដែលប្រគល់សញ្ញាបត្រ។ អ្នកពិនិត្យនិងវាយតម្លៃមកពីខាងក្រៅ អាចជាសាស្ត្រាចារ្យមកពីគ្រឹះស្ថានឧត្តមសិក្សា នៅកម្ពុជាឬបរទេស។ ក្នុងករណីដែលបេក្ខជនបណ្ឌិតជាបុគ្គលិកនៃគ្រឹះស្ថានឧត្តមសិក្សា ដែលប្រគល់សញ្ញាបត្រ អ្នកពិនិត្យនិងវាយតម្លៃខាងក្នុងគ្រឹះស្ថានឧត្តមសិក្សាមិនអាចជាសាច់ញាតិ មិត្តភក្តិ ឬអ្នករួមការងារជិតដិតនឹងបេក្ខជនបានឡើយ
- អ្នកពិនិត្យវាយតម្លៃ មិនអាចជាសាស្ត្រាចារ្យណែនាំនិស្សិតនោះបានឡើយ

- អ្នកពិនិត្យវាយតម្លៃនិក្ខេបបទ គឺជាអ្នកដែលពុំមានទំនាក់ទំនងបុគ្គល ទំនាក់ទំនងវិជ្ជាជីវៈ ឬជាប់កិច្ចសន្យាណាមួយ ជាមួយបេក្ខជនបណ្ឌិត ដែលអាចមានឥទ្ធិពលដល់ការវាយតម្លៃ។ អ្នកពិនិត្យវាយតម្លៃ ត្រូវស្ថិតក្នុងស្ថានភាពមួយ ដែលអាចផ្តល់នូវការវាយតម្លៃដ៏សុក្រឹត លើគុណភាពនៃនិក្ខេបបទ។

១៤.៣- ដំណើរការការប្រឡងបញ្ចប់

- មុននឹងរៀបចំការការពារនិក្ខេបបទផ្ទាល់មាត់ គ្រឹះស្ថានឧត្តមសិក្សា ត្រូវផ្ញើនិក្ខេបបទដែលសរសេរចប់សម្រាប់ឡើងការពារទៅអ្នកពិនិត្យវាយតម្លៃនិក្ខេបបទ
- ជាទូទៅ ក្រោយពីបានបំពេញគ្រប់លក្ខខណ្ឌសម្រាប់ការការពារ បេក្ខជនបណ្ឌិតត្រូវធ្វើការការពារនិក្ខេបបទផ្ទាល់មាត់ ដោយផ្ទាល់និងជាសាធារណៈ។

មាត្រា ១៥.-

ការពិនិត្យនិងវាយតម្លៃនិក្ខេបបទ មានដូចខាងក្រោម៖

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវផ្ញើទៅគ្រប់អ្នកពិនិត្យវាយតម្លៃ នូវនិក្ខេបបទមួយច្បាប់ និងព័ត៌មានទាក់ទងនឹងតម្រូវការនានាដែលអ្នកពិនិត្យវាយតម្លៃត្រូវធ្វើ
- ការពិភាក្សាជូនដំណឹងគ្នា រវាងអ្នកពិនិត្យវាយតម្លៃ និងសាស្ត្រាចារ្យណែនាំ និងបេក្ខជនបណ្ឌិតត្រូវបានហាមឃាត់ជាដាច់ខាត មុនពេលរបាយការណ៍អំពីការវាយតម្លៃ មិនទាន់ដាក់ជូនផ្នែកទទួលបន្ទុកវគ្គបណ្ឌិត ឬគណៈកម្មការគ្រប់គ្រងវគ្គបណ្ឌិត
- ដំណើរការប្រឡងបញ្ចប់ ត្រូវចប់សព្វគ្រប់ នៅពេលបញ្ចប់ការការពារផ្ទាល់មាត់។ រាល់អនុសាសន៍ដែលបេក្ខជនបណ្ឌិតទទួលបានមុនពេលនោះ គឺជាអនុសាសន៍បណ្តោះអាសន្នប៉ុណ្ណោះ
- បន្ទាប់ពីការពិនិត្យពិចារណាលើនិក្ខេបបទ អ្នកពិនិត្យ និងវាយតម្លៃ និក្ខេបបទ ត្រូវសរសេររបាយការណ៍ទៅគ្រឹះស្ថានឧត្តមសិក្សា។ របាយការណ៍របស់អ្នកពិនិត្យវាយតម្លៃនិក្ខេបបទ គឺជារបាយការណ៍ឯករាជ្យរៀងៗខ្លួន។

មាត្រា ១៦.-

ការរៀបចំទូទៅនៃការប្រឡងបញ្ចប់ មានដូចខាងក្រោម៖

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានការពន្យល់ច្បាស់លាស់អំពីដំណើរការប្រឡងបញ្ចប់ ចាប់តាំងពីការចាប់ផ្តើមរបស់អ្នកពិនិត្យនិងវាយតម្លៃ រហូតដល់លទ្ធផលចុងក្រោយនៃការការពារផ្ទាល់មាត់។ ការពន្យល់នេះត្រូវចែកជូនដល់គ្រប់ភាគីពាក់ព័ន្ធ
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានទម្រង់ជាលាយលក្ខណ៍អក្សរងាយយល់និងច្បាស់លាស់ សម្រាប់បំពេញដើម្បីជួយដំណើរការរដ្ឋបាល នៃកិច្ចការប្រឡងបញ្ចប់
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានការទទួលខុសត្រូវ ក្នុងការរៀបចំការការពារផ្ទាល់មាត់ ដែលស្ថិតក្នុងពេលវេលាមួយត្រឹមត្រូវ និងច្បាស់លាស់
- ការការពារផ្ទាល់មាត់ ត្រូវស្ថិតនៅក្នុងបរិយាកាសសមស្រប ទីតាំងសក្តិសម មានសម្ភារៈគ្រប់គ្រាន់និងស្វាគមន៍ការចូលរួមស្តាប់ជាសាធារណៈ។

មាត្រា ១៧.-

ការរៀបចំមុន សម្រាប់ការការពារផ្ទាល់មាត់ មានដូចខាងក្រោម៖

- ប្រធានផ្នែកបណ្ឌិត ឬព្រឹទ្ធបុរសនៃថ្នាក់ក្រោយបរិញ្ញាបត្រ ផ្ញើលទ្ធផលនៃការអាន និងវាយតម្លៃរបស់អ្នកពិនិត្យវាយតម្លៃ ទៅក្រុមសាស្ត្រាចារ្យណែនាំ គណៈមេប្រយោគ និងនិស្សិតយ៉ាងតិច ៣០(សាមសិប)ថ្ងៃ មុនថ្ងៃឡើងការពារផ្ទាល់មាត់
- ការការពារផ្ទាល់មាត់ រៀបចំដោយប្រធានផ្នែកបណ្ឌិត ឬព្រឹទ្ធបុរសនៃថ្នាក់ក្រោយបរិញ្ញាបត្រ និងដែលជាប្រធានដឹកនាំការការពារផ្ទាល់មាត់។ ប្រធានផ្នែកបណ្ឌិត ឬព្រឹទ្ធបុរសនៃថ្នាក់ក្រោយបរិញ្ញាបត្រ អាចចាត់អ្នកតំណាងក្នុងករណីពុំអាចចូលរួមដឹកនាំបាន
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវព្យាយាមឲ្យមានការចូលរួម ពីសំណាក់អ្នកពិនិត្យវាយតម្លៃនិក្ខេបបទទាំងអស់ ក្នុងពេលការពារផ្ទាល់មាត់។ ករណីចាំបាច់ ត្រូវប្រើបច្ចេកវិទ្យាព័ត៌មានជាពិសេសសម្រាប់អ្នកពិនិត្យវាយតម្លៃមកពីបរទេស។ ក្នុងករណី អ្នកពិនិត្យវាយតម្លៃ មកពីបរទេសអវត្តមាន សំណួរទាំងអស់របស់គាត់ ត្រូវបានលើកយកមកចោទសួរ ក្នុងការការពារផ្ទាល់មាត់។ ក្រុមសាស្ត្រាចារ្យណែនាំត្រូវចូលរួមក្នុងការការពារផ្ទាល់មាត់ផងដែរ។ សាស្ត្រាចារ្យណែនាំគោល ដើរតួជាគណៈមេប្រយោគម្នាក់ដែរក្នុងការផ្តល់ពិន្ទុ
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវកំណត់នីតិវិធី សម្រាប់អនុវត្តនៅពេលដែលអ្នកពិនិត្យ និងវាយតម្លៃពុំឯកភាពគ្នា លើលទ្ធផលនៃការប្រឡងបញ្ចប់។

មាត្រា ១៨.-

ការរៀបចំសម្រាប់អំឡុងពេល ការពារផ្ទាល់មាត់ មានដូចខាងក្រោម៖

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានការកំណត់របៀប នៃការការពារផ្ទាល់មាត់នូវនិក្ខេបបទថ្នាក់បណ្ឌិតផ្សេងៗគ្នា អាស្រ័យតាមជំនាញ
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានរបាយការណ៍វាយតម្លៃដំបូង ជាលាយលក្ខណ៍អក្សរខ្លី រៀបចំឡើងដោយមានលក្ខណឯករាជ្យ ពីសំណាក់អ្នកពិនិត្យវាយតម្លៃនិក្ខេបបទ មុនពេលការពារផ្ទាល់មាត់ ដាក់ជូនគណៈមេប្រយោគទាំងអស់
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានការកំណត់ជាមុន នូវតារាងលទ្ធផលប្រឡង ដើម្បីឲ្យគណៈមេប្រយោគងាយស្រួលមានយោបល់ និងដាក់ពិន្ទុ និងដើម្បីរក្សាស្តង់ដាគុណភាពថ្នាក់បណ្ឌិត
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានការកំណត់នីតិវិធីគ្រប់ដំណាក់កាល នៃដំណើរការប្រឡងដែលច្បាស់លាស់ និងងាយយល់។ ការកំណត់នេះ មានដូចជា៖
  - ក- ការកំណត់និយាមនៃដំណើរការប្រឡង។
  - ខ- ការកំណត់តួនាទី ភារកិច្ច និងការទទួលខុសត្រូវ របស់អ្នកពិនិត្យ និងវាយតម្លៃមកពីក្រៅ និងអ្នកពិនិត្យនិងវាយតម្លៃមកពីក្នុងគ្រឹះស្ថានឧត្តមសិក្សា សាស្ត្រាចារ្យណែនាំ និងគណៈមេប្រយោគនៅពេលការពារផ្ទាល់មាត់។
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានគោលការណ៍ណែនាំ អំពីការការពារផ្ទាល់មាត់ ដែលផ្តោតទៅលើ៖
  - ក- ទម្រង់និងកាលវិភាគនៃការការពារផ្ទាល់មាត់។
  - ខ- រយៈពេលរួមនៃការការពារផ្ទាល់មាត់។
  - គ- ការផ្តល់អនុសាសន៍ទៅបេក្ខជន នៅចុងបញ្ចប់នៃការការពារផ្ទាល់មាត់។

មាត្រា ១៩..

របាយការណ៍ក្រោយការការពារផ្ទាល់មាត់ មានដូចខាងក្រោម៖

- សេចក្តីសម្រេចរបស់គណៈមេប្រយោគអាច មានមួយក្នុងចំណោមចំណុច ខាងក្រោម៖
  ក- និក្ខេបបទមានតម្លៃ ជានិក្ខេបបទកម្រិតបណ្ឌិត។
  ខ- និក្ខេបបទមានតម្លៃ ជានិក្ខេបបទកម្រិតបណ្ឌិត បន្ទាប់ពីមានការកែលម្អតិចតួច តាមការណែនាំរបស់មេប្រយោគ។ ក្នុងករណីនេះ និស្សិតនិងសាស្ត្រាចារ្យណែនាំធ្វើការកែលម្អ និងដាក់ជូនគ្រឹះស្ថានឧត្តមសិក្សាឡើងវិញ តាមការព្រមព្រៀងគ្នា។
  គ- និក្ខេបបទមានតម្លៃជានិក្ខេបបទកម្រិតបណ្ឌិត បន្ទាប់ពីមានការកែសម្រួលឡើងវិញ តាមការណែនាំរបស់មេប្រយោគ។ ក្នុងករណីនេះ និស្សិតនិងសាស្ត្រាចារ្យណែនាំ ត្រូវធ្វើការសរសេរកែលម្អឡើងវិញ និងដាក់ជូនគ្រឹះស្ថានឧត្តមសិក្សា តាមការព្រមព្រៀងគ្នាជាមួយនឹងគណៈមេប្រយោគ។
  ឃ- និក្ខេបបទពុំទាន់មានតម្លៃជានិក្ខេបបទកម្រិតបណ្ឌិត ក៏ប៉ុន្តែបេក្ខជនអាចដាក់និក្ខេបបទ ដើម្បីពិនិត្យនិងវាយតម្លៃម្តងទៀត ក្នុងរយៈពេលដែលកំណត់ ដោយគណៈមេប្រយោគ។ ក្នុងករណីនេះ មេប្រយោគត្រូវរៀបរាប់ពន្យល់លម្អិត អំពីមូលហេតុនិងអនុសាសន៍របស់ខ្លួន ឲ្យបានក្បោះក្បាយ ដើម្បីជួយបេក្ខជន ក្នុងការទទួលបានជោគជ័យនាគ្រាក្រោយ។ និស្សិតនិងសាស្ត្រាចារ្យណែនាំ ត្រូវធ្វើការស្រាវជ្រាវ ឬសរសេរឡើងវិញតាមការផ្តល់អនុសាសន៍ ដែលបានព្រមព្រៀងគ្នាជាមួយនឹងគណៈមេប្រយោគ មុនពេលកំណត់ថ្ងៃការពារផ្ទាល់មាត់ ឡើងវិញម្តងទៀត។
  ង- សញ្ញាបត្របណ្ឌិត មិនត្រូវបានប្រគល់ជូន ហើយការចុះឈ្មោះជាបេក្ខជនបណ្ឌិត ត្រូវបានបញ្ចប់។
- នៅពេលដែលមេប្រយោគមានយោបល់ និងការវាយតម្លៃផ្សេងៗគ្នា លើលទ្ធផលនៃការប្រឡងបញ្ចប់ អ្នកវាយតម្លៃខាងក្នុង ត្រូវដើរតួជាអ្នកសម្របសម្រួល រវាងមេប្រយោគទាំងអស់ ដើម្បីដោះស្រាយបញ្ហា។ របាយការណ៍ចុងក្រោយរួមគ្នា និងឯកភាពគ្នាមួយ ត្រូវរៀបចំឡើងជូនប្រធានថ្នាក់បណ្ឌិត (ឬព្រឹទ្ធបុរស នៃថ្នាក់ក្រោយបរិញ្ញាបត្រ) ដោយអ្នកសម្របសម្រួល។ ក្នុងករណីពុំមានការឯកភាពគ្នាទេ ត្រូវយកមធ្យមភាគនៃពិន្ទុ ដែលផ្តល់ឲ្យដោយគណៈមេប្រយោគទាំងអស់ជាលទ្ធផលក្នុងការចេញសញ្ញាបត្របណ្ឌិត
- មេប្រយោគទាំងអស់ ត្រូវមានការឯកភាពគ្នា និងចុះហត្ថលេខាលើរបាយការណ៍ នៃការការពារផ្ទាល់មាត់
- ប្រធានផ្នែកបណ្ឌិត ឬព្រឹទ្ធបុរសនៃថ្នាក់ក្រោយបរិញ្ញាបត្រ ដែលជាប្រធានគណៈកម្មការការពារបន្ទាប់ពីការការពារផ្ទាល់មាត់ ត្រូវធ្វើរបាយការណ៍អំពីលទ្ធផល នៃការប្រឡងជារួមទៅគណៈកម្មការគ្រប់គ្រងថ្នាក់បណ្ឌិត
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានយន្តការប្តឹងតវ៉ា ក្នុងករណីដែលនិស្សិត ឬសាស្ត្រាចារ្យណែនាំ ពុំយល់ព្រមលើលទ្ធផលនៃការប្រឡង។

ជំពូកទី៤
លក្ខខណ្ឌសម្រាប់ការផ្តល់សញ្ញាបត្របណ្ឌិតកិត្តិយស

មាត្រា ២០.-

គ្រឹះស្ថានឧត្តមសិក្សា ដែលផ្តល់សញ្ញាបត្របណ្ឌិតកិត្តិយស ត្រូវមានលក្ខណសម្បត្តិ ដូចខាងក្រោម៖

- មានតែគ្រឹះស្ថានឧត្តមសិក្សា ដែលបានទទួលស្គាល់គុណភាពអប់រំពេញសិទ្ធិ ពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ឬគណៈកម្មាធិការជាតិបណ្តុះបណ្តាល ដែលនិងធ្លាប់បានប្រគល់សញ្ញាបត្របណ្ឌិតប៉ុណ្ណោះ ទើបអាច ផ្តល់សញ្ញាបត្របណ្ឌិតកិត្តិយសបាន
- គ្រឹះស្ថានឧត្តមសិក្សា អាចផ្តល់សញ្ញាបត្របណ្ឌិតកិត្តិយសបាន តែនៅក្នុងជំនាញដែលមានការបណ្តុះបណ្តាល នៅក្នុងគ្រឹះស្ថានឧត្តមសិក្សានោះ តែប៉ុណ្ណោះ
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវបង្កើតគណៈកម្មការ សម្រាប់បណ្ឌិតកិត្តិយស។ សមាសភាពនៃគណៈកម្មការនេះ ត្រូវចម្លងជូនជ្រាបទៅក្រសួងទទួលបន្ទុកវិស័យអប់រំ និងគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ឬគណៈកម្មាធិការជាតិ បណ្តុះបណ្តាល
- ក្នុងមួយឆ្នាំសិក្សា គ្រឹះស្ថានឧត្តមសិក្សាមួយ អាចផ្តល់សញ្ញាបត្របណ្ឌិតកិត្តិយស ជូនទៅត្រឹមតែបេក្ខជន២(ពីរ)រូប ប៉ុណ្ណោះ។

មាត្រា ២១.-

គោលការណ៍នៃការជ្រើសរើសបេក្ខជន ទទួលសញ្ញាបត្របណ្ឌិតកិត្តិយស មានដូចខាងក្រោម៖

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវកំណត់ឲ្យបានច្បាស់លាស់ និងផ្សព្វផ្សាយជាសាធារណៈ នូវគោលការណ៍នៃការប្រគល់សញ្ញាបត្របណ្ឌិតកិត្តិយស
- បេក្ខជនទទួលសញ្ញាបត្របណ្ឌិតកិត្តិយស ពុំអាចជាអ្នករាជការសាធារណៈ ដែលកំពុងស្ថិតក្នុងតំណែងសំខាន់ មានឥទ្ធិពលដោយផ្ទាល់លើគ្រឹះស្ថានឧត្តមសិក្សា ដែលប្រគល់សញ្ញាបត្របណ្ឌិតកិត្តិយសឡើយ
- បេក្ខជនទទួលសញ្ញាបត្រប់ណ្ឌិតកិត្តិយស ពុំអាចជានិស្សិតដែលកំពុងសិក្សា ឬជាមន្ត្រីដែលកំពុងបម្រើការក្នុងគ្រឹះស្ថានឧត្តមសិក្សានោះបានឡើយ
- សញ្ញាបត្របណ្ឌិតកិត្តិយស ពុំត្រូវបានអនុញ្ញាតឲ្យប្រគល់ជូន ដើម្បីដោះដូរនឹងប្រាក់ លាភសក្ការៈ ឬសេវាកម្មណាមួយសម្រាប់គ្រឹះស្ថានឧត្តមសិក្សាឡើយ។ លើកលែងតែសកម្មភាពសប្បុរសធម៌ក្នុងអតីតកាល និងអនាគតក្នុងរយៈពេលវែងពុំមែនជាឧបសគ្គ ក្នុងការប្រគល់សញ្ញាបត្របណ្ឌិតកិត្តិយសនេះទេ
- សញ្ញាបត្របណ្ឌិតកិត្តិយសគួរ ត្រូវប្រគល់ជូនបុគ្គលដែលបានរួមវិភាគទាន ក្នុងការកសាងព្រះរាជាណាចក្រកម្ពុជាជាចម្បង។

មាត្រា ២២.-

ការជ្រើសរើសបេក្ខជន សម្រាប់ផ្តល់សញ្ញាបត្របណ្ឌិតកិត្តិយស ត្រូវអនុវត្តដូចខាងក្រោម៖

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវកំណត់ឲ្យបានច្បាស់លាស់ និងផ្សាយជាសាធារណៈពីកាលបរិច្ឆេទចុងក្រោយសម្រាប់៖
  - ក- ប្រធានផ្នែកក្រោយបរិញ្ញាបត្រ ឬផ្នែកបណ្ឌិតនៃគ្រឹះស្ថានឧត្តមសិក្សា ទទួលការស្នើតាំងបេក្ខជន ពីសាស្ត្រាចារ្យ។
  - ខ- បញ្ជីឈ្មោះនៃបេក្ខជន ដែលបានស្នើតាំងទាំងអស់ សម្រាប់ឆ្នាំសិក្សា ដើម្បីដាក់ជូននាយកគ្រឹះស្ថានឧត្តមសិក្សា និងជូនអង្គប្រជុំវាយតម្លៃសម្រេច។
  - គ- សំណុំឯកសារសម្រាប់បេក្ខជន ដែលបានស្នើតាំងផ្តាច់ព្រ័ត្រ សម្រាប់ការប្រជុំចុងក្រោយ។
  - ឃ-ការប្រជុំសម្រេចចុងក្រោយ។
- ការស្នើតាំងនីមួយៗ ត្រូវឆ្លងកាត់គណៈកម្មការជ្រើសរើស ដើម្បីធ្វើការវាយតម្លៃជម្រុះបេក្ខជនខ្លះ
- បេក្ខជន ដែលត្រូវបានដាប់ក្នុងបញ្ជីស្នើតាំងផ្តាច់ព្រ័ត្រ ត្រូវឆ្លងកាត់ការប្រជុំវាយតម្លៃចុងក្រោយ ការប្រជុំវាយតម្លៃនេះ ធ្វើការសម្រេចចិត្តឡើង ដោយផ្អែកលើលទ្ធផល នៃការពិនិត្យ និងវាយតម្លៃរបស់អនុគណៈកម្មការសម្រាប់បេក្ខជន ដែលបានស្នើតាំងនីមួយៗ
- អនុគណៈកម្មការពិនិត្យ និងវាយតម្លៃលើបេក្ខជន ដែលបានស្នើតាំងនីមួយៗ មានតួនាទីរៀបចំសំណុំឯកសារ សម្រាប់បេក្ខជនដែលបានស្នើតាំងម្នាក់។ សំណុំឯកសារនេះមានរៀបរាប់អំពីអាជីព និងស្នាដៃសំខាន់ៗរបស់បេក្ខជន ដែលបានស្នើតាំងផ្តាច់ព្រ័ត្រ និងជំនាញដែលត្រូវប្រគល់ជូន
- សេចក្តីសម្រេចចិត្តចុងក្រោយ ធ្វើឡើងតាមរយៈការបោះឆ្នោត របស់សមាជិកទាំងអស់ នៃគណៈ-កម្មការជ្រើសរើស។ សមាជិកដែលអវត្តមាន ត្រូវប្រគល់សិទ្ធិសម្រេចជូនប្រធានអង្គប្រជុំ ជាលាយលក្ខណ៍អក្សរ។ សញ្ញាបត្របណ្ឌិតកិត្តិយស អាចប្រគល់ជូនតែចំពោះបេក្ខជន ដែលទទួលបានសំឡេងគាំទ្រ ចាប់ពី២ភាគ៣ ឡើងទៅ
- ការប្រជុំសម្រេចចុងក្រោយ នៅកម្រិតគ្រឹះស្ថានឧត្តមសិក្សា មិនត្រូវធ្វើឡើងជាចំហ ឬជាសាធារណៈឡើយ
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវស្នើសុំការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យអប់រំ ដើម្បីចេញសញ្ញា-បត្របណ្ឌិតកិត្តិយស ជូនបេក្ខជន ក្រោយពីពេលការសម្រេចជាចុងក្រោយរួចរាល់។

មាត្រា ២៣.-

គោលការណ៍នៃការរៀបចំឯកសារពាក់ព័ន្ធ និងការប្រគល់សញ្ញាបត្របណ្ឌិតកិត្តិយស អាចមានភាពប្រែប្រួលពីបេក្ខជន ដែលបានស្នើតាំងចុងក្រោយម្នាក់ ទៅបេក្ខជនដែលបានស្នើតាំងចុងក្រោយម្នាក់ទៀត អាស្រ័យដោយព័ត៌មានដែលបានទទួល។ ទោះជាយ៉ាងណាក្តី សំណុំឯកសារសម្រាប់បេក្ខជន ដែលបានស្នើតាំងចុងក្រោយម្នាក់ៗដែលមិនអាចខ្វះបាន មានដូចខាងក្រោម៖

១- ប្រវត្តិរូបរបស់បេក្ខជន ដែលបានស្នើតាំងចុងក្រោយ ដែលបរិយាយអំពីការអប់រំ ការងារ រង្វាន់ និងការលើកទឹកចិត្តនានា។

២- ការវិភាគនិងវាយតម្លៃលើជោគជ័យ ឬស្នាដៃរបស់បេក្ខជន ដែលបានស្នើតាំងចុងក្រោយ ដោយមានការបញ្ជាក់ថា តើជោគជ័យឬស្នាដៃនោះមានទំនាក់ទំនងយ៉ាងណា ជាមួយគ្រឹះស្ថានឧត្តមសិក្សា ជាមួយកម្ពុជា ឬជាមួយមនុស្សជាតិទាំងមូល។

ជំពូកទី៥
យន្តការត្រួតពិនិត្យដើម្បីធានាគុណភាពលើការបណ្តុះបណ្តាលថ្នាក់បណ្ឌិត

មាត្រា ២៤.-

ក្របខ័ណ្ឌនៃការត្រួតពិនិត្យទូទៅ នៃវគ្គបណ្តុះបណ្តាលថ្នាក់បណ្ឌិត ត្រូវធ្វើឡើងដោយផ្អែកលើបីចំណុចសំខាន់ៗ ដូចខាងក្រោម៖

១- រដ្ឋបាលនិងការគ្រប់គ្រងរបស់គ្រឹះស្ថានឧត្តមសិក្សា។

២- ការស្រាវជ្រាវនិងការផ្សព្វផ្សាយរបស់គ្រឹះស្ថានឧត្តមសិក្សា។

៣- ការបណ្តុះបណ្តាលរបស់គ្រឹះស្ថានឧត្តមសិក្សា។

មាត្រា ២៥.-

កម្មវត្ថុនៃការត្រួតពិនិត្យមាន ដូចខាងក្រោម៖

- ការត្រួតពិនិត្យលើរដ្ឋបាលនិងការគ្រប់គ្រង ធ្វើការវាយតម្លៃលើភាពសមស្របនៃ ទីតាំងសិក្សាសមាសភាពសាស្ត្រាចារ្យ និងធនធានហិរញ្ញវត្ថុ ដែលអាចធានាឲ្យមានដំណើរការ នៃវគ្គបណ្តុះបណ្តាលមួយប្រកបដោយគុណភាព
- ការត្រួតពិនិត្យលើការស្រាវជ្រាវ និងផ្សព្វផ្សាយរបស់គ្រឹះស្ថានឧត្តមសិក្សា ធ្វើការវាយតម្លៃលើការបង្កើតអង្គភាពស្រាវជ្រាវ ដំណើរការស្រាវជ្រាវ និងការផ្សព្វផ្សាយរបស់គ្រឹះស្ថានឧត្តមសិក្សា។ គ្រឹះស្ថានឧត្តមសិក្សា ដែលដំណើរការបណ្តុះបណ្តាលថ្នាក់បណ្ឌិត ត្រូវមានអង្គភាពស្រាវជ្រាវដែលផ្សារភ្ជាប់ការងាររបស់ខ្លួនយ៉ាងសកម្ម ជាមួយផ្នែកបណ្តុះបណ្តាល។ រៀងរាល់លទ្ធផលនៃកិច្ចការស្រាវជ្រាវ ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ ដើម្បីជាប្រយោជន៍ដល់អ្នកសិក្សាស្រាវជ្រាវឯទៀត។ ការផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវ របស់គ្រឹះស្ថានឧត្តមសិក្សា ដែលដំណើរការថ្នាក់បណ្ឌិត អាចធ្វើតាមរយៈរូបភាពផ្សេងៗ ជាអាទិ៍ ទស្សនាវដ្តីប្រចាំឆ្នាំ (ឬឆមាស ឬត្រីមាស) ឯកសារពិភាក្សាសិក្ខាសាលាជំនាញ ឬតាមរូបភាពផ្សេងៗទៀត
- ការត្រួតពិនិត្យលើការបណ្តុះបណ្តាល ធ្វើការវាយតម្លៃលើគ្រប់ដំណាក់កាល នៃការបណ្តុះបណ្តាល គិតចាប់ពីការប្រឡងជ្រើសរើសនិស្សិត ការសិក្សាជាមួយនឹងសាស្ត្រាចារ្យ ការស្រាវជ្រាវ ការសរសេរនិក្ខេបបទ និងការប្រឡងបញ្ចប់វគ្គសិក្សា។ ការត្រួតពិនិត្យការបណ្តុះបណ្តាលថ្នាក់បណ្ឌិត ត្រូវធ្វើឡើងដោយឈរលើគោលការណ៍ធានាគុណភាពកម្រិតបណ្ឌិត នៅព្រះរាជាណាចក្រកម្ពុជា ភាពឯករាជ្យផ្នែកវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងការកាត់បន្ថយឲ្យបានជាអតិបរមា នូវកម្រិតការិយាធិបតេយ្យសំដៅធានាឲ្យមានប្រសិទ្ធភាពខ្ពស់ ក្នុងការគ្រប់គ្រងពេលវេលា និងធនធាននៃការបណ្តុះបណ្តាល។

មាត្រា ២៦.-

យន្តការត្រួតពិនិត្យនិងវាយតម្លៃគុណភាព មានដូចខាងក្រោម៖

- យន្តការត្រួតពិនិត្យដើម្បីធានាគុណភាព លើការបណ្តុះបណ្តាលថ្នាក់បណ្ឌិត ជាកិច្ចសហការរវាងក្រសួងទទួលបន្ទុកវិស័យអប់រំ ជាមួយក្រសួង ស្ថាប័នដែលមានគ្រឹះស្ថានឧត្តមសិក្សាបណ្តុះបណ្តាលថ្នាក់បណ្ឌិត
- គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ត្រូវមាននាយកដ្ឋានទទួលស្គាល់គុណភាពអប់រំថ្នាក់ក្រោយបរិញ្ញាបត្រ ដើម្បីវាយតម្លៃទទួលស្គាល់គុណភាពថ្នាក់បណ្ឌិត និងសហការ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការកំណត់ស្តង់ដាគុណភាពអប់រំអប្បបរមា សម្រាប់ការវាយតម្លៃទទួលស្គាល់គុណភាពថ្នាក់បណ្ឌិត។

មាត្រា ២៧.-

ការលើកកម្ពស់កិច្ចការស្រាវជ្រាវ មានដូចខាងក្រោម៖

- កិច្ចការស្រាវជ្រាវ គឺជាលក្ខខណ្ឌចាំបាច់មួយ ដែលមិនអាចខ្វះបាន ក្នុងគ្រឹះស្ថានឧត្តមសិក្សាជាពិសេសគ្រឹះស្ថានឧត្តមសិក្សាដែលមានបណ្តុះបណ្តាលថ្នាក់បណ្ឌិត។ គ្រប់ក្រសួង ស្ថាប័ន ត្រូវបង្កើតបរិយាកាសឲ្យគ្រឹះស្ថានឧត្តមសិក្សា ជំរុញសកម្មភាពស្រាវជ្រាវរបស់ខ្លួន តាមរយៈគ្រប់រូបភាព
- ទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវដើរតួជាអ្នកសម្របសម្រួលថវិកាជាតិ សម្រាប់ការស្រាវជ្រាវ និងសកម្មភាពស្រាវជ្រាវកម្រិតជាតិ ដែលមានលក្ខណៈលំបាកស្មុគស្មាញ។

មាត្រា ២៨.-

- សេចក្តីណែនាំលម្អិតពាក់ព័ន្ធនឹងដំណើរការបណ្តុះបណ្តាលថ្នាក់បណ្ឌិត និងយន្តការត្រួតពិនិត្យគុណភាពបណ្តុះបណ្តាលថ្នាក់បណ្ឌិត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យអប់រំ
- ស្តង់ដាគុណភាពអប្បបរមានិងយន្តការវាយតម្លៃ ដើម្បីទទួលស្គាល់គុណភាពថ្នាក់បណ្ឌិត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- ស្តង់ដាជាតិសមត្ថភាពបណ្តុះបណ្តាលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល។

ជំពូកទី៦

អន្តរប្បញ្ញត្តិ

មាត្រា ២៩.-

គ្រឹះស្ថានឧត្តមសិក្សា ដែលកំពុងដំណើរការបណ្តុះបណ្តាលថ្នាក់បណ្ឌិតនាពេលបច្ចុប្បន្ន មានរយៈពេល ១ (មួយ) ឆ្នាំ ដើម្បីកែលម្អឲ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

គ្រឹះស្ថានឧត្តមសិក្សា ដែលទើបចាប់ផ្តើមបើកដំណើរការបណ្តុះបណ្តាលថ្នាក់បណ្ឌិត ត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងអនុក្រឹត្យនេះ មុននឹងដំណើរការបណ្តុះបណ្តាល។

ប្រធានបទស្រាវជ្រាវរបស់និស្សិតថ្នាក់បណ្ឌិត ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ របស់គណៈកម្មាធិការជាតិរៀបចំគោលការណ៍ណែនាំ និងនីតិវិធីក្នុងការដឹកនាំការការពារសារណា និងនិក្ខេបបទ។

ជំពូកទី៧

អវសានប្បញ្ញត្តិ

មាត្រា ៣០.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣១.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៤១ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយសហមេត្រី តាមលំដាប់ថ្នាក់ ជូនអ្នកជំនាញការបរទេស ចំនួន០៦រូប ដែលមានស្នាដៃល្អក្នុងការធ្វើសហប្រតិបត្តិការ ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើការងារការពារសុខភាពសត្វ និងជួយអភិវឌ្ឍន៍វិស័យកៅស៊ូ និងព្រៃឈើ ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយសហមេត្រី ថ្នាក់ សេនា:

-លោក Tran Viet Hung

ខ-មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ:

១-លោក Peter A Windsor

២-លោក Luzia Rast

៣-លោក Phan Duc Thanh

៤-លោក Nguyen Khanh Hong

៥-លោក Nguyen Dac Kien

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ MAR

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១១៤២ .អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ មេបញ្ជាការកងទ័ពជើងគោក

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយការងារ តាមលំដាប់ថ្នាក់ ជូនកងឯកភាព ចំនួន៣២ និងនាយទាហាន នាយទាហានរង ពលទាហាន ចំនួន៣០៥រូប ចំណុះតំបន់ប្រតិបត្តិការសឹករងបាត់ដំបង ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ ជាច្រើនឆ្នាំកន្លងមក ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមាសការងារៈ

-ចំពោះកងឯកភាព

១-វរសេនាតូចការពារព្រំដែន ៥០៦	តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
២-វរសេនាតូចការពារព្រំដែន ៥០៩	តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៣-ផ្នែកសឹករង កំរៀង	តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៤-ផ្នែកសឹករង បាណន់	តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៥-ផ្នែកសឹករង រុក្ខគិរី	តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៦-ការិយាល័យទី ៣	តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៧-ការិយាល័យទី ៤	តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៨-លេខាធិការដ្ឋាន	តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៩-ផ្នែកហិរញ្ញវត្ថុ	តំបន់ប្រតិបត្តិការសឹករងបាត់ដំបង

- ចំពោះបុគ្គល

១-	វរសេនីយ៍ត្រី	យ៉ាន	យ៉ុន	០១០៩១៥	មេបញ្ជាការ ផ្នែកសឹករងឯកភ្នំ
២-	វរសេនីយ៍ត្រី	អ៊ុំ	ចាន់តារុណា	០១៦៤៤៣	មេបញ្ជាការ ផ្នែកសឹករងភ្នំព្រឹក
៣-	អនុសេនីយ៍ឯក	ជា	ចេន	០៣០៨៧៥	មេបញ្ជាការ វរសេនាតូចលេខ ៣ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៤-	អនុសេនីយ៍ឯក	ម៉ៀច	យន	០១៦៤៤១	នាយរងការិយាល័យទី៣ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៥-	អនុសេនីយ៍ឯក	ឡាច	សារ៉ាន់	០៤២៦២៦	នាយរងការិយាល័យទី៥ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៦-	អនុសេនីយ៍ឯក	ម៉ី	ថាវី	០៤២៦០០	នាយរងការិយាល័យទី៥ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៧-	អនុសេនីយ៍ឯក	ស៊ីម	ឡាយ	០៣១២១៥	មេបញ្ជាការរង ផ្នែកសឹករងថ្មគោល
៨-	អនុសេនីយ៍ឯក	ហ៊ាន	ប៊ុនធឿន	០៤២៦០៦	មេបញ្ជាការរង ផ្នែកសឹករងថ្មគោល
៩-	អនុសេនីយ៍ឯក	តួច	សុផាត	០៤២៦៣២	មេបញ្ជាការរង ផ្នែកសឹករងសង្កែ
១០-	អនុសេនីយ៍ឯក	ញាណា	សារ៉េន	០១៦៤៤៥	មេបញ្ជាការរង ផ្នែកសឹករងកំរៀង
១១-	អនុសេនីយ៍ឯក	តាត់	ឌឿន	០១៦៤៤៦	មេបញ្ជាការរង ផ្នែកសឹករងកំរៀង
១២-	អនុសេនីយ៍ឯក	ពេញ	ប៊ុននី	០២១៣៤៦	មេបញ្ជាការរង ផ្នែកសឹករងកំរៀង
១៣-	អនុសេនីយ៍ឯក	ម៉ាត់	ស្រួច	០១៦៤០៧	មេបញ្ជាការរង ផ្នែកសឹករងបាណន់
១៤-	អនុសេនីយ៍ឯក	នុត	ហ៊ាច	០៩០៣០៥	មេបញ្ជាការរង ផ្នែកសឹករងមោងឫស្សី
១៥-	អនុសេនីយ៍ឯក	នួន	ប៊ុនសាត់	០៩០៣០៥	មេបញ្ជាការរង ផ្នែកសឹករងមោងឫស្សី
១៦-	អនុសេនីយ៍ឯក	សេខ	សុផល	០១៦៤៣២	មេបញ្ជាការរង ផ្នែកសឹករងឯកភ្នំ
១៧-	អនុសេនីយ៍ឯក	គ្រៀល	សាឯម	០១៦៧៣៣	មេបញ្ជាការរង ផ្នែកសឹករងឯកភ្នំ
១៨-	អនុសេនីយ៍ឯក	ស៊ិន	គឹមសាន	០១៩៥២៤	មេបញ្ជាការរង ផ្នែកសឹករងគាស់ក្រឡ
១៩-	អនុសេនីយ៍ឯក	ស៊ីន	សំណាង	០៣០៩៩៥	មេបញ្ជាការរង ផ្នែកសឹករងគាស់ក្រឡ
២០-	អនុសេនីយ៍ឯក	ឆៅ	ផាត	០៣០៩០២	មេបញ្ជាការរង ផ្នែកសឹករងឯកភ្នំ
២១-	អនុសេនីយ៍ឯក	ជួប	សុខុម	០៤២៥៩៧	នាយរង ផ្នែកហិរញ្ញវត្ថុ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
២២-	អនុសេនីយ៍ឯក	ឈុំ	សារ៉េន	០៥៥១៩០	ជំនួយការ សោធន-សរសើរ ការិយាល័យទី១ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
២៣-	អនុសេនីយ៍ឯក	ស៊ុន	នីន	០៣០៨៤៥	ជំនួយការ តែងតាំង ការិយាល័យទី១ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
២៤-	អនុសេនីយ៍ឯក	ព្រហ្ម	វិចិត្រ	០៣០៨៧៦	ជំនួយការ តែងតាំង ការិយាល័យទី១ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
២៥-	អនុសេនីយ៍ឯក	តួច	សារ៉ាត់	០៤២៦១៥	ជំនួយការ ផែនការ ការិយាល័យទី៤ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
២៦-	អនុសេនីយ៍ឯក	ស៊ី	ពន្លក	០៤៣៥៤៧	ជំនួយការ បរិក្ខា ការិយាល័យទី៤ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
២៧-	អនុសេនីយ៍ឯក	យឹម	សែ	០៣០៨៦៥	នាយផ្នែកបច្ចេកទេស តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
២៨-	អនុសេនីយ៍ឯក	កែវ	មាស	០៣០៨៦៤	នាយផ្នែកស្នៃកម្ម តំបន់ប្រតិបត្តិការសឹករងបាត់ដំបង

២៩-	អនុសេនីយ៍ឯក	ទិន	សេន	០៤២៦១២	នាយផ្នែកបំភ័ន្តអក្ខរៈ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៣០-	អនុសេនីយ៍ទោ	ម៉ៃ	ផាច	០៣០៨៩៩	មេបញ្ជាការរង វរសេនាតូចការពារព្រំដែន ៥០៩
៣១-	អនុសេនីយ៍ទោ	អោម	កើន	០៣០៩០១	នាយសេនាធិការ វរសេនាតូចការពារព្រំដែន ៥០៩
៣២-	អនុសេនីយ៍ទោ	ឈិន	ប៊ាន	០៣០៨៨០	មេបញ្ជាការ គ វរសេនាតូចការពារព្រំដែន ៥០៩
៣៣-	អនុសេនីយ៍ទោ	ម៉ូ	តា	០២២៩០២	មេបញ្ជាការរង ផ្នែកសឹករងសំឡូត
៣៤-	អនុសេនីយ៍ទោ	ជា	សុធី	០៥៥១៨៦	មេបញ្ជាការរង ផ្នែកសឹករងមោងឫស្សី
៣៥-	អនុសេនីយ៍ទោ	ទ្រាំ	ស៊ីដេត	០៦២៧១៧	ជំនួយការបូកសរុបការិយាល័យទី៣ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៣៦-	អនុសេនីយ៍ទោ	ស្នួម	សឿន	០៤២៦៥០	នាយសេនាធិការ វរសេនាតូចលេខ ៣
៣៧-	អនុសេនីយ៍ទោ	ឡាយ	ហាម	០៦១១៥៧	ជំនួយការ ស្បៀង ការិយាល័យទី៤ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៣៨-	អនុសេនីយ៍ទោ	ម៉ែន	ម៉ាន	០៤២៦១៧	ជំនួយការ សព្វាវុធ ការិយាល័យទី៤ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៣៩-	អនុសេនីយ៍ទោ	ទឿន	ធីន	០៦២៦០៦	ជំនួយការ ប្រេង ការិយាល័យទី៤ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៤០-	អនុសេនីយ៍ទោ	ណាម	ណោត	០៧៧០៩៦	ជំនួយការ ដឹកជញ្ជូន ការិយាល័យទី៤ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៤១-	អនុសេនីយ៍ទោ	ហ៊ុន	ប៊ុននី	០៣៧៣២០	នាយរង ផ្នែកវិស្វកម្ម តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៤២-	អនុសេនីយ៍ទោ	យឿត	សុផ្លាទី	០៦២៥៧៣	ជំនួយការ គោលនយោបាយ ការិយាល័យទី៥ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៤៣-	អនុសេនីយ៍ទោ	តួច	វិសាល	០៨១៧១៩	ជំនួយការ កីឡា ការិយាល័យហ្វឹកហ្វឺន តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៤៤-	អនុសេនីយ៍ទោ	ស្វ	តិរម្យ	០៧៧១៤៦	ជំនួយការហិរញ្ញវត្ថុ ផ្នែកសឹករងសំឡូត
៤៥-	អនុសេនីយ៍ទោ	ម្វ	ភ្វ	០៣២៨៣២	ជំនួយការហិរញ្ញវត្ថុ ផ្នែកសឹករងកំរៀង
៤៦-	អនុសេនីយ៍ទោ	កែម	ធី	០២១៣៨៧	មេបញ្ជាការ គ ផ្នែកសឹករងកំរៀង
៤៧-	អនុសេនីយ៍ទោ	សុខ	គីមចាយ	០៣២៨៤៤	មេបញ្ជាការរង គ ផ្នែកសឹករងកំរៀង
៤៨-	អនុសេនីយ៍ទោ	សេខ	ម៉ុនណារិទ្ធ	០៩៤០១៣	មេបញ្ជាការរង គ ផ្នែកសឹករងកំរៀង
៤៩-	អនុសេនីយ៍ទោ	សោម	ចន្ថា	០២១៣០៨	ជំនួយការបុគ្គលិក ផ្នែកសឹករងសំពៅលូន
៥០-	អនុសេនីយ៍ទោ	រិន	រឿត	១៦១១៧៦	ជំនួយការ បុគ្គលិក វរសេនាតូចការពារព្រំដែន៥០៦
៥១-	អនុសេនីយ៍ទោ	ផន	សោ	០៣០៩០៣	មេបញ្ជាការ គ១ វរសេនាតូចការពារព្រំដែន៥០៦
៥២-	អនុសេនីយ៍ទោ	គង់	ម៉ូរ៉ា	០៣០៨៥៦	មេបញ្ជាការរង គ១ វរសេនាតូចការពារព្រំដែន៥០៦
៥៣-	អនុសេនីយ៍ទោ	ណាន	វណ្ណី	០៣០៨៩២	មេបញ្ជាការ គ២ វរសេនាតូចការពារព្រំដែន៥០៦
៥៤-	អនុសេនីយ៍ទោ	ណុប	សែម	០៣០៨៨៣	មេបញ្ជាការ គ៣ វរសេនាតូចការពារព្រំដែន៥០៦
៥៥-	អនុសេនីយ៍ទោ	ស្ងួន	ស៊ុន	០៣០៨៨៧	មេបញ្ជាការរង គ៣ វរសេនាតូចការពារព្រំដែន៥០៦
៥៦-	អនុសេនីយ៍ទោ	អ៊ួន	សុឃឿន	២១៤០៤៣	មេបញ្ជាការរង គ៣ វរសេនាតូចការពារព្រំដែន៥០៦
៥៧-	អនុសេនីយ៍ត្រី	គុំ	សោរិទ្ធ	០៥៥១២៧	មេបញ្ជាការរង ផ្នែកសឹករងបាត់ដំបង

៥៨-	អនុសេនីយ៍ត្រី	**យឹម**	**ពៅ**	០៧៧០៨០	មេបញ្ជាការ ខ បញ្ជូនសារ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៥៩-	អនុសេនីយ៍ត្រី	**ស៊ុន**	**ឧុន្នី**	០៦២៥៧៩	គ្រូពេទ្យ គិលានដ្ឋាន តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៦០-	អនុសេនីយ៍ត្រី	**ម៉ាត់**	**លេម៉ាន**	០៤២៦៥១	មេបញ្ជាការរង គ២យ៣ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៦១-	អនុសេនីយ៍ត្រី	**សួស**	**សាឡឿន**	០៣២៨៣០	ជំនួយការចលនូប្បត្ថម្ភ ផ្នែកសឹករងកំរៀង
៦២-	អនុសេនីយ៍ត្រី	**មឿន**	**រុន**	០៣២២២៨	មេបញ្ជាការរង គ ផ្នែកសឹករងកំរៀង
៦៣-	នាយចំណង់	**លៀប**	**ដៀប**	០៧៧០៨៣	បុគ្គលិក គិលានដ្ឋាន តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៦៤-	នាយចំណង់	**កេត**	**វណ្ណារ៉ា**	០៥៥០៧៥	បុគ្គលិក គិលានដ្ឋាន តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៦៥-	នាយចំណង់	**អ៊ុច**	**សំបូរ**	០៦២៦៤៧	បុគ្គលិក ប្រតិបត្តិការសឹក ផ្នែកសឹករងថ្មគោល
៦៦-	នាយចំណង់	**ប៉េង**	**ពិសិដ្ឋ**	១១០៩៩៣	បុគ្គលិក ចិត្តសាស្ត្រ ផ្នែកសឹករងថ្មគោល
៦៧-	នាយចំណង់	**គោត**	**សុខុន**	០៥៥១២១	ជំនួយការចលនូប្បត្ថម្ភ ផ្នែកសឹករងបាត់ដំបង
៦៨-	នាយចំណង់	**គង់**	**សឹម**	០៥៥២២៥	ជំនួយការ បុគ្គលិក វរសេនាតូចការពារព្រំដែន៥០៩
៦៩-	នាយចំណង់	**កែវ**	**បូរ៉ាត់**	០៦២៧០០	ជ.ប្រតិបត្តិការសឹក វរសេនាតូចការពារព្រំដែន៥០៩
៧០-	នាយចំណង់	**ព្រហ្ម**	**ណារ័ត្ន**	០៥៥២០៣	មេបញ្ជាការ គ២យ៣ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៧១-	នាយចំណង់	**គង់**	**សំរេច**	០៥៥១៨២	ជំនួយការ បុគ្គលិក ផ្នែកសឹករងមោងឫស្សី
៧២-	នាយចំណង់	**មុន្នី**	**សោភ័ណ្ឌ**	០៥៥១៧៤	ជំនួយការ បុគ្គលិក ផ្នែកសឹករងឯកភ្នំ
៧៣-	ព្រិន្ទបាលឯក	**ប្រាក់**	**សារិទ្ធ**	១១៦៦៨៤	ផ្នែកបញ្ជូនសារ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង

ខ-មេដាយប្រាក់ការងារ:

- **ចំពោះកងឯកភាព**

១- ផ្នែកសឹករង ក្រុងបាត់ដំបង — តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
២- ផ្នែកសឹករង ថ្មគោល — តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៣- ផ្នែកសឹករង ភ្នំព្រឹក — តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៤- ការិយាល័យយោធាតំបន់ — តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៥- ការិយាល័យហ្វឹកហ្វឺន — តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៦- គិលានដ្ឋាន — តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៧- កងអនុសេនាតូចបញ្ជូនសារ — តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៨- កងអនុសេនាតូចស៊ើបការការពារ — តំបន់ប្រតិបត្តិការសឹករងបាត់ដំបង

- **ចំពោះបុគ្គល**

១-	អនុសេនីយ៍ឯក	**ឈឺន**	**គង់**	០១៦៤២៩	មេបញ្ជាការរង ផ្នែកសឹករងរតនមណ្ឌល
២-	អនុសេនីយ៍ឯក	**ឡឹក**	**វណ្ណា**	០១៦៤១៨	មេបញ្ជាការរង ផ្នែកសឹករងរតនមណ្ឌល
៣-	អនុសេនីយ៍ឯក	**សែម**	**បូរ**	០១៦៤១១	មេបញ្ជាការរង ផ្នែកសឹករងបវេល
៤-	អនុសេនីយ៍ឯក	**មុយ**	**ចន្ថា**	០១១៨២២	មេបញ្ជាការរង ផ្នែកសឹករងសំពៅលូន

៥-	អនុសេនីយ៍ឯក	យី	ឡឿន	០៣០៩០៨	មេបញ្ជាការរង ផ្នែកសឹករងភ្នំព្រឹក
៦-	អនុសេនីយ៍ឯក	ឌិប	ផាឌិប	០៥៥០៨៣	ជំនួយការ ឯកសារ ការិយាល័យទី ១
៧-	អនុសេនីយ៍ទោ	អៀង	ឡេង	០៣៣៦៥២	មេបញ្ជាការរង ផ្នែកសឹករងរុក្ខគីរី
៨-	អនុសេនីយ៍ទោ	យិន	សុត	០៣០៨៨២	មេបញ្ជាការ គ២ វរសេនាតូចការពារព្រំដែន៥០៩
៩-	អនុសេនីយ៍ទោ	កៅ	សុខា	០៨២៥៩៨	ជំនួយការ ហិរញ្ញវត្ថុ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
១០-	អនុសេនីយ៍ទោ	ម៉ម	សុខា	០១០៥០១	ជំនួយការ ហិរញ្ញវត្ថុ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
១១-	អនុសេនីយ៍ទោ	នៅ	តិរុណា	០៣៧២៣១	ជំនួយការបុគ្គលិក កា.ទី១ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
១២-	អនុសេនីយ៍ទោ	ម៉ែត	សាលី	០៨២៦១០	ជំនួយការផែនការ ការិយាល័យទី ៣
១៣-	អនុសេនីយ៍ទោ	ស៊ាន	រ៉ូសេត	១១០៦៨៩	ជំនួយការបូកសរុប ការិយាល័យទី ៣
១៤-	អនុសេនីយ៍ទោ	យុត	សុភ័ណ្ឌ	០៥៥១១១	ជំនួយការហិរញ្ញវត្ថុ វរសេនាតូចលេខ៣
១៥-	អនុសេនីយ៍ទោ	សុខ	បូរឿន	១១០៦៩៨	ជំនួយការបំភ័ន្តអក្ខរៈ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
១៦-	អនុសេនីយ៍ទោ	គឹម	វិចិត្រ	០២១៣២៣	មេបញ្ជាការ គ ផ្នែកសឹករងភ្នំព្រឹក
១៧	អនុសេនីយ៍ត្រី	ខន្ធ	សាវៃ	០៨៦១៨០	ជំនួយការ វិន័យទណ្ឌកម្ម ការិយាល័យទី ១
១៨-	អនុសេនីយ៍ត្រី	សុធី	ស្ថាបនា	០៦២៧០៦	ជំនួយការ បរិក្ខា ការិយាល័យទី ៤
១៩-	អនុសេនីយ៍ត្រី	ខាន់	ផល្គុណា	០៨៣៩៩៣	ជំនួយការ បច្ចេកទេស តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
២០-	អនុសេនីយ៍ត្រី	និត្យ	សុភាព	០៨៦៨៦២	ជំនួយការ ព័ត៌មាន.ឯកសារ ការិយាល័យទី ៥
២១-	អនុសេនីយ៍ត្រី	អ៊ុំ	សារ៉ែន	០៧៧១២៩	ជំនួយការ កសិដ្ឋាន ការិយាល័យអភិវឌ្ឍន៍
២២-	អនុសេនីយ៍ត្រី	យ៉ម	សារិទ្ធ	០៧៧០៨២	ជំនួយការ យន្តយុទ្ធ ការិយាល័យយោធាតំបន់
២៣-	អនុសេនីយ៍ត្រី	ស	លី	០៦២៥៨៧	ជំនួយការប្រតិបត្តិការសឹក ការិយាល័យយោធាតំបន់
២៤-	អនុសេនីយ៍ត្រី	ប៊ុន	ធឿន	០៣២៧០០	មេបញ្ជាការរង ខ២ គ ផ្នែកសឹករងសំពៅលូន
២៥-	អនុសេនីយ៍ត្រី	អួង	វណ្ណី	០៨៣៥៨៩	មេបញ្ជាការរង គ២ វរសេនាតូចព្រំដែនលេខ៥០៦
២៦-	អនុសេនីយ៍ត្រី	នេង	ប៊ុនសឹង	០៨៣៥៥១	មេបញ្ជាការរង គ៣ វរសេនាតូចព្រំដែនលេខ៥០៦
២៧-	នាយចំណង់	អ៊ុក	ស៊ីថា	០៦២៦២៣	មេបញ្ជាការរង ខ បញ្ជូនសារ
២៨-	នាយចំណង់	រស់	កុសល	០៧៧០៩៨	បុគ្គលិក បើកបរ ការិយាល័យទី ៤
២៩-	នាយចំណង់	ធឿន	ថា	០៩០៩២៥	ជំនួយការបច្ចេកទេស ការិយាល័យទី ៤
៣០-	នាយចំណង់	អ៊ិន	សំអុល	០៨៦៥៨២	ជំនួយការ អប់រំចិត្តសាស្ត្រ ការិយាល័យទី ៥
៣១-	នាយចំណង់	ឯក	រ៉ា	០៦២៦៥១	ជំនួយការ អប់រំចិត្តសាស្ត្រ ការិយាល័យទី ៥
៣២-	នាយចំណង់	ឈាង	ហ៊ាត់	០៨១៦៣៥	ជំនួយការ ហ្វឹកហ្វឺន ការិយាល័យហ្វឹកហ្វឺន
៣៣-	នាយចំណង់	ថន	សុផា	០៥៣៩៩០	ជំនួយការ ហ្វឹកហ្វឺន ការិយាល័យហ្វឹកហ្វឺន

៣៤-	នាយចំណង់	ភ័ណ្ឌា	កែវទិចិត្រ	០៥៥២៤២	ជំនួយការ ហិរញ្ញ ហ៊ឹកហ្វឺន ការិយាល័យហ៊ឹកហ្វឺន
៣៥-	នាយចំណង់	ប៉ោយ	ម៉ិនថា	១៦១២៦៤	ជំនួយការ បុគ្គលិក ផ្នែកសឹករង សំឡូត
៣៦-	នាយចំណង់	ស្រី	សារី	០៦២៧១៤	ជំនួយការ បុគ្គលិក ផ្នែកសឹករង គាស់ក្រឡ
៣៧-	នាយចំណង់	កែវ	ភូមិរិទ្ធ	១៦១២៦៨	មេបញ្ជាការរង គ ផ្នែកសឹករង សំឡូត
៣៨-	នាយចំណង់	ភួង	សំអឿន	០៨១៦៩៣	ជំនួយការ ហ៊ឹកហ្វឺន ផ្នែកសឹករង ថ្មគោល
៣៩-	នាយចំណង់	គឹម	ហឿន	០៩១០០៥	បំរើការ ផ្នែកសឹករង ថ្មគោល
៤០-	នាយចំណង់	នូ	សារ៉ែន	០៩១០០៣	ជំនួយការ ហ៊ឹកហ្វឺន ផ្នែកសឹករង ថ្មគោល
៤១-	នាយចំណង់	យឿន	ណាង	១១០៩៦៩	ជំនួយការ ជីវពល ផ្នែកសឹករង ថ្មគោល
៤២-	នាយចំណង់	ស៊ីន	ជឿន	០៦២៦៥៩	ជំនួយការ ហិរញ្ញវត្ថុ ផ្នែកសឹករង រុក្ខគិរី
៤៣-	នាយចំណង់	ទីន	លក្ខា	០៥៥១៦៩	ជំនួយការ ហិរញ្ញវត្ថុ ផ្នែកសឹករង ឯកភ្នំ
៤៤-	នាយចំណង់	ជា	សុខុន	០៥៥១៧៣	ជំនួយការ ចិត្តសាស្ត្រ ផ្នែកសឹករង ឯកភ្នំ
៤៥-	នាយចំណង់	យូ	សុខុន	០៥៥១៧០	ជំនួយការ ហ៊ឹកហ្វឺន ផ្នែកសឹករង ឯកភ្នំ
៤៦-	នាយចំណង់	ឡុង	សុខលី	០៥៥១៩៣	ជំនួយការ បុគ្គលិក វរសេនាតូចលេខ៣
៤៧-	នាយចំណង់	ស៊ុន	ពៅ	០៥៥២៣៩	មេបញ្ជាការរង គ២ វរសេនាតូចការពារព្រំដែន៥០៩
៤៨-	នាយចំណង់	សៅ	សេក	០៥៥១៤៥	ជំនួយការចលនូប្បត្តម្ភ វរសេនាតូចការពារព្រំដែន៥០៩
៤៩-	នាយចំណង់	សុន	ពេញ	០៥៥១៩៩	មេបញ្ជាការរង គ ១ វរសេនាតូច ៣
៥០-	នាយចំណង់	មួន	ម៉ាង	០៩១០៣៥	មេបញ្ជាការរង គ ១ វរសេនាតូច ៣
៥១-	នាយចំណង់	ប្រែង	វៀង	០៧៧២៧១	មេបញ្ជាការរង គ៣ វរសេនាតូចការពារព្រំដែន៥០៦
៥២-	នាយចំណង់	ហួត	ណែត	០៥៥២៣៧	មេបញ្ជាការរង គ១ វរសេនាតូចការពារព្រំដែន៥០៦
៥៣-	នាយចំណង់	សួម	ឈួម	០៥៥២៦០	មេបញ្ជាការរង គគាំទ្រ វរសេនាតូចការពារព្រំដែន៥០៦
៥៤-	នាយចំណង់	សួន	ចៃ	០៥៥២៣១	មេបញ្ជាការខ១ គ២ វរសេនាតូចការពារព្រំដែន៥០៦
៥៥-	ព្រិន្ទបាលឯក	ចាន់	សុខុម	១១០៦៩៩	មេរងក្រុម ខ បញ្ជូនសារ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៥៦-	ព្រិន្ទបាលឯក	អ៊ុន	សារឿន	០៦២៥៨២	គ្រូពេទ្យគិលានដ្ឋាន តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៥៧-	ព្រិន្ទបាលឯក	អឿន	ភិក្សា	០៨២១៥៧	ជំនួយការ ព័ត៌មាន ឯកសារ ការិយាល័យទី ៥
៥៨-	ព្រិន្ទបាលឯក	ពេជ្រ	សុវណ្ណា	០៨១៨៥៩	ជំនួយការ សិល្បៈ ការិយាល័យទី៥
៥៩-	ព្រិន្ទបាលឯក	ជឿន	ចន្ថា	០៧៧២៨៩	ជំនួយការ សិល្បៈ ការិយាល័យទី៥
៦០-	ព្រិន្ទបាលឯក	ម៉ក់	ម៉ៅ	០៦២៦១៥	ជំនួយការហ៊ឹកហ្វឺន ផ្នែកសឹករងរុក្ខគិរី
៦១-	ព្រិន្ទបាលឯក	ទឹក	នី	០៦២៦៥៧	យុទ្ធជន ខ បញ្ជូនសារ
៦២-	ព្រិន្ទបាលឯក	ស៊ីត	សឿត	០៦២៦៩៥	បុគ្គលិក ពេទ្យ វរសេនាតូចការពារព្រំដែន៥០៦

៦៣-	ព្រិន្ទបាលទោ	អឿន	ឡើត	១១០៩៥៧	យុទ្ធជន ខ បញ្ជូនសារ
៦៤-	ព្រិន្ទបាលទោ	សៀង	ឯមនិលរ័ត្ន	០៧៧៤២៣	ជំនួយការ បុគ្គលិក ផ្នែកសឹករងបាត់ដំបង
៦៥-	ព្រិន្ទបាលទោ	ឡឿន	នេត្រា	០៧៧៣៥៥	មេបញ្ជាការរង ខ DKZ គ គាំទ្រ វរសេនាតូចការពារព្រំដែន៥០៦
៦៦-	ព្រិន្ទបាលទោ	គុយ	យឹម	០៧៧១០៧	មេបញ្ជាការ ខ គ ៣ វរសេនាតូចការពារព្រំដែន៥០៦
៦៧-	ពលបាលឯក	មៀន	សំណាង	០៧៧០៩០	មេក្រុម ខ ការពារស៊ើបការ តំបន់ប្រតិបត្តិការសឹកបាត់ដំបង

គ-មេដាយសំរឹទ្ធភាពខារ:

- **ចំពោះអង្គភាព**

១- វរសេនាតូចលេខ ៣	តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
២- ផ្នែកសឹករង សំឡូត	តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៣- ផ្នែកសឹករង សំពៅលូន	តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៤- ផ្នែកសឹករង គាល់ក្រឡ	តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៥- ផ្នែកសឹករង មោងឫស្សី	តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៦- ផ្នែកសឹករង រតនមណ្ឌល	តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៧- ផ្នែកសឹករង សង្កែ	តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៨- ផ្នែកសឹករង ឯកភ្នំ	តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៩- ផ្នែកសឹករង បវេល	តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
១០-ការិយាល័យទី ១	តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
១១- ការិយាល័យទី ២	តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
១២- ការិយាល័យទី ៥	តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
១៣- ផ្នែកវិស្វកម្ម	តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
១៤- ផ្នែកបច្ចេកទេស	តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
១៥- ផ្នែកបំភ័ន្តអក្ខរៈ	តំបន់ប្រតិបត្តិការសឹករងបាត់ដំបង

- **ចំពោះបុគ្គល:**

១-	អនុសេនីយ៍ឯក	រោង	សារឹម	១១១៩៨៩	មេបញ្ជាការរង ផ្នែកសឹករងសំពៅលូន
២-	អនុសេនីយ៍ឯក	ចាន់	ខ្លា	០១១២២៣	មេបញ្ជាការរង ផ្នែកសឹករងឯកភ្នំ
៣-	អនុសេនីយ៍ឯក	អ៊ុក	គង់ម៉ុនឡើន	០៤២១៧៦	ជំនួយការ ចលនូបត្ថម្ភ ផ្នែកសឹករងបាណន់
៤-	អនុសេនីយ៍ទោ	សុខ	ផាង	០១៦៤៤០	ជំនួយការ ប្រតិបត្តិការសឹក ផ្នែកសឹករងគាស់ក្រឡ
៥-	អនុសេនីយ៍ទោ	ឈៀង	ប៉ាន់	០២១៣៨២	ជំនួយការ បុគ្គលិក ផ្នែកសឹករងកំរៀង
៦-	អនុសេនីយ៍ទោ	នួន	យូន	០៣២៧៩០	មេបញ្ជាការរង គ ផ្នែកសឹករងកំរៀង
៧-	អនុសេនីយ៍ទោ	សល់	ឧស្សាហ៍	០២២៩៩៤	ជំនួយការ ចិត្តសាស្ត្រ ផ្នែកសឹករងសំពៅលូន
៨-	អនុសេនីយ៍ទោ	ម៉ម	វ៉ន	០២១៣១៣	មេបញ្ជាការ ខ២ គ ផ្នែកសឹករងសំពៅលូន

៩-	អនុសេនីយ៍ទោ	អោម	យ៉ុង	០២១៣៥០	មេបញ្ជាការរង គ ផ្នែកសឹករងភ្នំព្រឹក
១០-	អនុសេនីយ៍ទោ	ទ៉ាន់	នី	០៣២៦៨១	មេបញ្ជាការរង គ ផ្នែកសឹករងភ្នំព្រឹក
១១-	អនុសេនីយ៍ទោ	អ៊ឹម	ម៉ៅ	០២១២៩០	មេបញ្ជាការរង គ ផ្នែកសឹករងភ្នំព្រឹក
១២-	អនុសេនីយ៍ទោ	សេរី	សាប់	០២១៣៦២	ជំនួយការបុគ្គលិក ផ្នែកសឹករងភ្នំព្រឹក
១៣-	អនុសេនីយ៍ទោ	ខឹម	សុធា	០២១៣៥៦	មេបញ្ជាការ ខ៣ គ ផ្នែកសឹករងភ្នំព្រឹក
១៤-	អនុសេនីយ៍ត្រី	ឈឹម	ឈុនហេង	១១០២៩៩	គ្រូពេទ្យគិលានដ្ឋាន តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
១៥-	អនុសេនីយ៍ត្រី	ម៉ុន	សារ៉េត	០៨១៦៣៩	ជំនួយការប្រតិបត្តិការសឹក ការិយាល័យទី៣
១៦-	អនុសេនីយ៍ត្រី	សាន	សុគុណា	០៨៦៥៦៨	ជំនួយការ អប់រំចិត្តសាស្ត្រ ការិយាល័យទី៥
១៧-	អនុសេនីយ៍ត្រី	ហាំ	ហឿន	០៨២៦៧០	ជំនួយការ ប្រតិបត្តិការសឹក ផ្នែកសឹករងសំឡូត
១៨-	អនុសេនីយ៍ត្រី	សេង	គឹមសាន	១៣០៨៧២	ជំនួយការ ផ្នែកសឹករងសង្កែ
១៩-	អនុសេនីយ៍ត្រី	ដេត	ដារិទ្ធ	០៨២៦១៣	ជំនួយការ ប្រតិបត្តិការសឹក ផ្នែកសឹករងបាណន់
២០-	អនុសេនីយ៍ត្រី	គិត	សុខ	០៨២៦៣៩	មេបញ្ជាការរង គ៣ វរសេនាតូចការពារព្រំដែន៥០៩
២១-	អនុសេនីយ៍ត្រី	ម៉ី	សុវណ្ណា	០៥៥២២៧	ជំនួយការហិរញ្ញវត្ថុ វរសេនាតូចការពារព្រំដែន៥០៩
២២-	អនុសេនីយ៍ត្រី	ញ៉ឹយ	គិត	០៣២៦៨២	មេបញ្ជាការរង ខ២ គ ផ្នែកសឹករងសំពៅលូន
២៣-	អនុសេនីយ៍ត្រី	ប៉ុល	នី	០៨៨០៥៦	មេបញ្ជាការរង ផ្នែកសឹករងកំរៀង
២៤-	អនុសេនីយ៍ត្រី	ញឹក	លួច	០៥៥២៦៧	ជំនួយការហិរញ្ញវត្ថុ ផ្នែកសឹករងបវេល
២៥-	អនុសេនីយ៍ត្រី	ស៊ិន	សម្បត្តិ	០៨៨៦៦៨	មេបញ្ជាការរង គ ផ្នែកសឹករងកំរៀង
២៦-	អនុសេនីយ៍ត្រី	យស	សាម៉ុត	០៦២៧២៨	មេបញ្ជាការរង គ ផ្នែកសឹករងកំរៀង
២៧-	អនុសេនីយ៍ត្រី	សំ	ពិសិដ្ឋ	០៨៨០៦០	មេបញ្ជាការរង ខ១ គ ផ្នែកសឹករងភ្នំព្រឹក
២៨-	អនុសេនីយ៍ត្រី	ណាង	ថាច	០៨៨០៨១	មេបញ្ជាការរង ខ២ គ ផ្នែកសឹករងភ្នំព្រឹក
២៩-	អនុសេនីយ៍ត្រី	តែ	សេងហួង	១១០៩៧២	ជំនួយការប្រតិបត្តិការ ផ្នែកសឹករងភ្នំព្រឹក
៣០-	អនុសេនីយ៍ត្រី	អ៊ុំ	ចិម៉ុល	០៨៨០៨៦	ជំនួយការចលនូប្បត្តម្ភ ផ្នែកសឹករងភ្នំព្រឹក
៣១-	នាយចំណង់	គឹម	ណារី	១១០៦៨៦	ជំនួយការ បណ្តុះបណ្តាល ការិយាល័យទី១
៣២-	នាយចំណង់	ហួ	រតនា	១១០៨០១	បុគ្គលិក គិលានដ្ឋាន តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៣៣-	នាយចំណង់	ថាប់	សុធានី	០៥៥០៧៩	បុគ្គលិក គិលានដ្ឋាន តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៣៤-	នាយចំណង់	កែវ	ជឿន	០៥៥៣០០	ជំនួយការចលនូប្បត្តម្ភ ផ្នែកសឹករងសំឡូត
៣៥-	នាយចំណង់	ធឿង	ឆន	០៥៥១៥៨	ជំនួយការបុគ្គលិក ផ្នែកសឹករងថ្មគោល
៣៦-	នាយចំណង់	គួង	សុផល	០៥៥១៦០	ជំនួយការចលនូប្បត្តម្ភ ផ្នែកសឹករងថ្មគោល
៣៧-	នាយចំណង់	អ៊ុង	សែន	០៥៥១៦១	ជំនួយការហិរញ្ញវត្ថុ ផ្នែកសឹករងថ្មគោល

៣៨-	នាយចំណាង	គា	សុខ	០៥៥១៦២	ជំនួយការជីវពល ផ្នែកសឹករងថ្មគោល
៣៩-	នាយចំណាង	ឥន្ទ	សុខា	០៥៥១៦៤	ជំនួយការប្រតិបត្តិការសឹក ផ្នែកសឹករងថ្មគោល
៤០-	នាយចំណាង	ឃ្លាំង	ស៊ីផុល	០៩១០១០	បុគ្គលិកពេទ្យ ផ្នែកសឹករងថ្មគោល
៤១-	នាយចំណាង	ឈិន	ម៉ៅល	០៨១៨១០	ជំនួយការប្រតិបត្តិការសឹក ផ្នែកសឹករងរុក្ខគីរី
៤២-	នាយចំណាង	សាន	យឿន	០៧៧៣៨៨	ជំនួយការយោធាតំបន់ ផ្នែកសឹករងរុក្ខគីរី
៤៣-	នាយចំណាង	ស្វគំ	សំអឿន	០៥៥២៨៣	ជំនួយការបុគ្គលិក ផ្នែកសឹករងរតនមណ្ឌល
៤៤-	នាយចំណាង	រ៉ែម	រុំខ	០៧៧៣៨៨	ជំនួយការជីវពល ផ្នែកសឹករងរតនមណ្ឌល
៤៥-	នាយចំណាង	ចរ	រុំម	០៦៧១៨៦	ជំនួយការចិត្តសាស្ត្រ ផ្នែកសឹករងរតនមណ្ឌល
៤៦-	នាយចំណាង	នេត្រ	សុផល	០៥៥២៨៧	ជំនួយការហ្វឹកហ្វឺន ផ្នែកសឹករងរតនមណ្ឌល
៤៧-	នាយចំណាង	ឆា	អេន	០៥៥២៨៦	ជំនួយការប្រតិបត្តិការសឹក ផ្នែកសឹករងរតនមណ្ឌល
៤៨-	នាយចំណាង	គឹម	ខុន	០៥៥២៩១	ជំនួយការចលនូប្បត្ថម្ភ ផ្នែកសឹករងរតនមណ្ឌល
៤៩-	នាយចំណាង	អ៊ូច	ដុំ	០៥៥២៨២	ជំនួយការហិរញ្ញវត្ថុ ផ្នែកសឹករងរតនមណ្ឌល
៥០-	នាយចំណាង	ឆាយ	ឡាយ	០៧៧១៨៧	ជំនួយការបុគ្គលិក ផ្នែកសឹករងបវេល
៥១-	នាយចំណាង	លឹម	គឿន	០៥៥២៦៩	ជំនួយការចលនូប្បត្ថម្ភ ផ្នែកសឹករងបវេល
-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩: -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្មស្របតាម បទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការ ចុះបញ្ជីផលិតផល ។/៣៥

ប្រការ១១: លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោម តាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាម មាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមាន ប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន ។

ប្រការ១៥: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- សាលារាជធានីភ្នំពេញ

  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ០២៥ សណន

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ វិច្ឆិកា ឆ្នាំ២០១០

សេចក្តីណែនាំ
ស្តីពី
វិធានការពង្រឹងការអនុវត្តការងារស្ថិតិ និងអត្រានុកូលដ្ឋាន

- យោងអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន។
- យោងអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការកែសំរួលមាត្រា ៨ និង មាត្រា ៥៩ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន។
- យោងអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០០២ ស្តីពីការកំណត់ថ្លៃជាវក្រដាសអត្រានុកូលដ្ឋាន។
- យោងអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន។
- យោងអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស។
- យោងសេចក្តីណែនាំលេខ ០០៨ សណន ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៧ របស់ក្រសួងមហាផ្ទៃ ស្តីពីការចុះសៀវភៅអត្រានុកូលដ្ឋានឱ្យមាននិរន្តរភាពក្រោយបញ្ចប់យុទ្ធនាការចុះសៀវភៅអត្រានុកូលដ្ឋានចល័ត។
- យោងសេចក្តីណែនាំលេខ ០០១សណន ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការអនុវត្តអនុក្រឹត្យស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស។

ចាប់តាំងពីបានដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងការងារស្ថិតិ និងអត្រានុកូលដ្ឋាន ជាបន្តបន្ទាប់ និងក្រោយពីយុទ្ធនាការនៃការចុះបញ្ជីអត្រានុកូលដ្ឋានចល័តបានបញ្ចប់ជាច្រើនឆ្នាំកន្លងមក រហូតដល់បច្ចុប្បន្ននេះ ក្រសួងមហាផ្ទៃ បានពិនិត្យឃើញថា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ភាគច្រើនបានខិតខំយកចិត្តទុកដាក់បន្តនិរន្តរភាពក្នុងការអនុវត្តការងារអត្រានុកូលដ្ឋានបានល្អប្រសើរ។ ទន្ទឹមនឹងទិន្នផលនៃការចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់មក ក្រសួងមហាផ្ទៃក៏បានសង្កេតឃើញថា នៅមានសាលាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់មួយចំនួនតូច ជាពិសេសមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ខ្លះពុំបានយកចិត្តទុកដាក់ជំរុញការចុះបញ្ជីអត្រានុកូលដ្ឋាន ចេញសំបុត្រអត្រានុកូលដ្ឋាន និងសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានមាន : កំណើត បញ្ជាក់កំណើត អាពាហ៍ពិពាហ៍ និងមរណភាព ជូនប្រជាពលរដ្ឋឱ្យបានត្រឹមត្រូវទៅតាមលិខិត

បទដ្ឋាន បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋានដែលមានជាធរមាននៅឡើយ ។ មិនត្រឹមតែប៉ុណ្ណោះ ក៏មានបាតុភាពខុសឆ្គងមួយចំនួនបានលេចឡើងជាបន្តបន្ទាប់ ដូចជា :

- មានសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម សេចក្ដីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងបញ្ជីនៃសៀវភៅអត្រានុកូលដ្ឋានជាច្រើនត្រូវបានកោស ឆូត លុប សរសេរជ្រៀតបន្ថែម និងកែនៅលើទិន្នន័យសំខាន់ៗដូចជា នាមត្រកូល នាមខ្លួន ភេទ សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត ទីកន្លែងរៀបអាពាហ៍ពិពាហ៍ ទីកន្លែងមរណភាពរបស់ សាមីខ្លួន និងរបស់ឪពុកម្ដាយជាដើម

- មានការចេញសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម ឬសេចក្ដីចម្លងសំបុត្រអត្រានុកូលដ្ឋានដោយពុំបានចុះក្នុងបញ្ជីនៃសៀវភៅអត្រានុកូលដ្ឋាន

- មានធ្វើការចុះបញ្ជីអត្រានុកូលដ្ឋានប្រភេទតែមួយ ឱ្យបុគ្គលតែម្នាក់ ដែលធ្លាប់បានចុះបញ្ជីនៅក្នុងឃុំ សង្កាត់ផ្សេង រួចម្ដងមកហើយ

- បានចុះបញ្ជីអត្រានុកូលដ្ឋានឱ្យបុគ្គលដែលមានទីលំនៅមិនពិតប្រាកដ ឬទើបមកស្នាក់នៅថ្មីក្នុងឃុំ សង្កាត់របស់ខ្លួន ដោយគ្មានឯកសារបញ្ជាក់គ្រប់គ្រាន់ ត្រឹមត្រូវ ច្បាស់លាស់

- មានមេឃុំ ចៅសង្កាត់ខ្លះទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសដោយគ្មានលិខិតជូនដំណឹងពីក្រសួងមហាផ្ទៃ ឬបានធ្វើការចុះបញ្ជីអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស មុនពេលទទួលបានលិខិតជូនដំណឹងពីក្រសួងមហាផ្ទៃ និងពុំមានវត្តមានសាមីខ្លួនប្ដីប្រពន្ធ សាក្សីនៅចំពោះមុខមន្ត្រីអត្រានុ-កូលដ្ឋានទេ

- មានសាលាក្រុង ស្រុក ខណ្ឌមួយចំនួនបានចេញសេចក្ដីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទជូនប្រជាពលរដ្ឋ ដោយពុំបានយកសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម មកធ្វើការផ្ទៀងផ្ទាត់ ជាមួយនឹងបញ្ជីនៃសៀវភៅអត្រានុកូលដ្ឋានដែលបានតម្កល់ទុក។ ក្រៅពីនេះក៏មានយកក្រដាសសេចក្ដីចម្លងសំបុត្រអត្រានុកូលដ្ឋាន ដែលក្រសួងមហាផ្ទៃបានផ្ដល់ជូនជាផ្លូវការទៅថតចម្លង រួចចុះហត្ថលេខាបោះត្រាចម្លងចេញជូនប្រជាពលរដ្ឋ ប្រើប្រាស់ថែមទៀតផង...។ល។

ផ្ដើមចេញពីចំណុចខ្វះខាតខាងលើនេះ ក្រសួងមហាផ្ទៃសូមណែនាំដល់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ដែលជាមន្ត្រីអត្រានុកូលដ្ឋាន ស្មៀនឃុំ សង្កាត់ មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋានសាលាក្រុង ស្រុក ខណ្ឌ និងមន្ត្រីទទួលបន្ទុកការងារអត្រានុកូលដ្ឋានគ្រប់ថ្នាក់ ត្រូវធ្វើការត្រួតពិនិត្យលើការងារអត្រានុកូលដ្ឋាន និងយកចិត្តទុកដាក់កែលំអ និងបន្តអនុវត្តឱ្យបានត្រឹមត្រូវទៅតាមច្បាប់ អនុក្រឹត្យ សេចក្ដីណែនាំ បែបបទ និងនីតិវិធីពាក់ព័ន្ធ ដោយត្រូវបន្តអនុវត្តនូវវិធានការចាំបាច់មួយចំនួនដូចខាងក្រោម :

I- វិធានការចាំបាច់ដែលត្រូវបន្តអនុវត្ត

១- នៅថ្នាក់រាជធានី ខេត្ត

អភិបាលនៃគណៈអភិបាលរាជធានី ខេត្តដែលមានការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋានជាសេនាធិការត្រូវ :

- យកចិត្តទុកដាក់ គាំទ្រ ជំរុញ ត្រួតពិនិត្យ តាមដានឱ្យបានជាប្រចាំលើការងារស្ថិតិ និងអត្រានុកូលដ្ឋាន នៅតាមសាលាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់របស់ខ្លួន និងមានវិធានការកែលំអ ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវតាមលិខិតបទដ្ឋានដែលបានកំណត់

- គ្រប់គ្រង និងថែរក្សាទុកដាក់ឯកសារពាក់ព័ន្ធនឹងការទទួល និងបែងចែកសៀវភៅ និងក្រដាសអត្រានុ-កូលដ្ឋាន និងឯកសារពាក់ព័ន្ធគ្រប់ប្រភេទឱ្យបានត្រឹមត្រូវ

- គ្រប់គ្រង និងថែរក្សាទុកដាក់សៀវភៅអត្រានុកូលដ្ឋាន ដែលបានទទួលយកមកពីសាលាដំបូងរាជធានីខេត្តឱ្យបានគត់មត់ល្អ និងត្រូវរៀបចំទៅតាមប្រភេទនីមួយៗ តាមឈ្មោះក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់តាមលំដាប់ឆ្នាំ និងតាមលេខរៀងសៀវភៅឱ្យបានត្រឹមត្រូវ

- ធ្វើការត្រួតពិនិត្យ និងវាយតម្លៃអំពីសមត្ថភាពការងាររបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ និងមន្ត្រីទទួលបន្ទុកការងារអត្រានុកូលដ្ឋាននៅថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីធ្វើការគាំទ្រ និងធ្វើការបណ្តុះបណ្តាលលើការងារស្ថិតិ និងអត្រានុកូលដ្ឋាន

- បញ្ចូលខ្លឹមសារលទ្ធផលនៃការអនុវត្តការងារស្ថិតិ និងអត្រានុកូលដ្ឋាន ទៅក្នុងរាល់ការប្រជុំរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្ត និងត្រូវមានវិធានការដើម្បីរំលឹកដាស់តឿនដល់សាលាក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ អនុវត្តឱ្យបានជាប្រចាំ និងបានត្រឹមត្រូវតាមច្បាប់ អនុក្រឹត្យ សេចក្តីណែនាំ បែបបទ និងនីតិវិធីនៃ ការងារស្ថិតិ និងអត្រានុកូលដ្ឋាន

- រៀបចំកិច្ចប្រជុំការងារស្ថិតិ និងអត្រានុកូលដ្ឋាន ជាមួយក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងស្ថាប័នពាក់ព័ន្ធយ៉ាងតិច ១ ឆមាសម្តង

- ធ្វើរបាយការណ៍ស្តីពីការងារស្ថិតិ និងអត្រានុកូលដ្ឋាន ព្រមទាំងធ្វើការបូកសរុបបញ្ហាប្រឈមនានាដែលបានកើតឡើងផ្ញើជូនក្រសួងមហាផ្ទៃ ឱ្យបានទៀងទាត់ និងទាន់ពេលវេលាកំណត់។

២-នៅថ្នាក់ក្រុង ស្រុក ខណ្ឌ

ក-អំពីសៀវភៅអត្រានុកូលដ្ឋាន និងការចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដែលមានមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាននៅសាលាក្រុង ស្រុក ខណ្ឌ ជាជំនួយការ ត្រូវអនុវត្តនូវវិធានការចាំបាច់មួយចំនួនដូចខាងក្រោម ៖

- យកចិត្តទុកដាក់គាំទ្រ ជំរុញ ត្រួតពិនិត្យ និងតាមដានឱ្យបានជាប់ជាប្រចាំលើការងារស្ថិតិ និងអត្រានុកូលដ្ឋាននៅឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីជំរុញឱ្យឃុំ សង្កាត់ អនុវត្តឱ្យបានជាប់ជាប្រចាំ និងបានត្រឹមត្រូវ ស្របតាមលិខិតបទដ្ឋានដែលមានកន្លងមក

- ចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ ជូនប្រជាពលរដ្ឋប្រើប្រាស់ ឱ្យបានត្រឹមត្រូវទៅតាមបែបបទ និងនីតិវិធីដែលបានកំណត់

- គ្រប់គ្រង និងថែរក្សាសៀវភៅអត្រានុកូលដ្ឋានឆ្នាំចាស់ដែលកន្លងផុតទៅ ឱ្យបានគត់មត់ល្អ និងរៀបចំ៖

ទុកដាក់សៀវភៅអត្រានុកូលដ្ឋានឆ្នាំចាស់ដែលកន្លងផុតទៅតាមប្រភេទនីមួយៗ តាមឃុំ សង្កាត់ តាមលំដាប់ឆ្នាំ និងតាមលេខរៀងសៀវភៅឱ្យបានត្រឹមត្រូវ

- ទទួលខុសត្រូវក្នុងការទទួលសៀវភៅ ក្រដាសអត្រានុកូលដ្ឋាន និងឯកសារពាក់ព័ន្ធគ្រប់ប្រភេទពីសាលារាជធានី ខេត្ត និងពង្រឹងការគ្រប់គ្រង និងបែងចែកសៀវភៅ ក្រដាសអត្រានុកូលដ្ឋាន និងឯកសារពាក់ព័ន្ធគ្រប់ប្រភេទទៅឱ្យឃុំ សង្កាត់ឱ្យបានត្រឹមត្រូវ

- រៀបចំ និងផ្ញើសៀវភៅអត្រានុកូលដ្ឋានឆ្នាំចាស់ដែលកន្លងផុតទៅ តាមប្រភេទនីមួយៗ ០១ច្បាប់ទៅសាលារាជធានី ខេត្ត

- បញ្ចូលខ្លឹមសារលទ្ធផលនៃការអនុវត្តការងារស្ថិតិ និងអត្រានុកូលដ្ឋាន ទៅក្នុងរាល់ការប្រជុំរបស់ក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងត្រូវមានវិធានការដើម្បីរំលឹកដាស់តឿនដល់មន្ត្រីអត្រានុកូលដ្ឋាន មានមេឃុំ ចៅសង្កាត់ ស្មៀនឃុំ សង្កាត់ និងមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋានសាលាក្រុង ស្រុក ខណ្ឌ អនុវត្តឱ្យបានជាប្រចាំ និងបានត្រឹមត្រូវតាមច្បាប់ អនុក្រឹត្យ សេចក្តីណែនាំ បែបបទ និងនីតិវិធីនៃការងារស្ថិតិ និងអត្រានុកូលដ្ឋាន

- ធ្វើរបាយការណ៍ស្តីពីការងារស្ថិតិ និងអត្រានុកូលដ្ឋាន ព្រមទាំងធ្វើការបូកសរុបបញ្ហាប្រឈមនានាដែលបានកើតឡើង ផ្ញើជូនសាលារាជធានី ខេត្ត ឱ្យបានទាន់ពេលវេលាកំណត់។

ខ-ហាមឃាត់នូវទង្វើមួយចំនួនដូចខាងក្រោម :

- មិនត្រូវធ្វើការកែតម្រូវបញ្ជីនៃសៀវភៅអត្រានុកូលដ្ឋានដែលបានតម្កល់ទុក ដោយមិនអនុវត្តតាមអំណាចសាលក្រមស្ថាពររបស់តុលាការ ឬតាមបទប្បញ្ញត្តិច្បាប់ ឬដោយគ្មានអំណាចសាលក្រមស្ថាពររបស់តុលាការ

- មិនត្រូវធ្វើការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋ ខុសពីទិន្នន័យដែលមាននៅក្នុងបញ្ជីនៃសៀវភៅអត្រានុកូលដ្ឋានដែលបានតម្កល់ទុក

- មិនត្រូវធ្វើការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋ ដោយពុំបានយកសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម មកធ្វើការផ្ទៀងផ្ទាត់ជាមួយនឹងបញ្ជីនៃសៀវភៅអត្រានុកូលដ្ឋានដែលបានតម្កល់ទុក

- មិនត្រូវធ្វើការថតចម្លងលើក្រដាសសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម ដែលក្រសួងមហាផ្ទៃបានផ្តល់ជូន យកទៅថតចម្លង រួចចុះហត្ថលេខាបោះត្រាចម្លងចេញជូនប្រជាពលរដ្ឋប្រើប្រាស់

- មិនត្រូវតម្រូវឱ្យបង់ថ្លៃក្រដាស និងតែមប្រើលើសពីការកំណត់

- មិនត្រូវធ្វើការកោស ឆូត លុប ដោយប្រើទឹកលុប ហើយសរសេរជ្រៀតបន្ថែម ឬកែទិន្នន័យនៅលើបញ្ជីនៃសៀវភៅអត្រានុកូលដ្ឋាន ឬលើសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន។

៣-នៅថ្នាក់ឃុំ សង្កាត់

ក-អំពីការចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទ និងការងារពាក់ព័ន្ធស្ថិតិ និងអត្រានុកូលដ្ឋាន

មេឃុំ ចៅសង្កាត់ដែលត្រូវបានទទួលប្រតិភូកម្មជាមន្ត្រីអត្រានុកូលដ្ឋាន និងដោយមានស្មៀនឃុំ សង្កាត់ជាជំនួយការ ជាប្រចាំត្រូវធ្វើការអប់រំប្រជាពលរដ្ឋធ្វើការចុះបញ្ជីអត្រានុកូលដ្ឋានតាមច្បាប់ អនុក្រឹត្យ និងនីតិវិធីដែលបានកំណត់។ មេឃុំ ចៅសង្កាត់ មានភារកិច្ចចេញសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមគ្រប់ប្រភេទ ចេញសេចក្តី

ចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទក្នុងឆ្នាំមិនទាន់ដាច់ និងលិខិតបញ្ជាក់នានាដែលពាក់ព័ន្ធនឹងការងារអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋប្រើប្រាស់ឱ្យបានត្រឹមត្រូវទៅតាម ច្បាប់ អនុក្រឹត្យ សេចក្តីណែនាំ បែបបទ និងនីតិវិធីនៃការងារ អត្រានុកូលដ្ឋាន ដោយត្រូវអនុវត្តនូវវិធានការចាំបាច់សំខាន់ៗ ដូចខាងក្រោម :

- ត្រូវបន្ថយកចិត្តទុកដាក់ស្វែងយល់អំពីលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធនឹងការងារអត្រានុកូលដ្ឋាន ជាពិសេសកម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន ដើម្បីជៀសវាងការអនុវត្តខុសឆ្គងដែលកើតមានកន្លងមក ជាដដែលៗ

- ត្រូវចេញលិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ ដោយកំណត់សុពលភាពរយៈពេលបីខែ ដោយមានបិទរូបថតថ្មី ទំហំ ៤ x ៦ មួយសន្លឹកផង

- រាល់ការអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ ដែលអាចប្រព្រឹត្តទៅបាន លុះត្រាតែប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ត្រូវបានបិទប្រកាសជាសាធារណៈរយៈពេល១០ថ្ងៃ ដោយគ្មានការប្តឹងតវ៉ា

- ត្រូវផ្ញើសៀវភៅអត្រានុកូលដ្ឋានឆ្នាំចាស់ដែលកន្លងផុតទៅ ទៅសាលាក្រុង ស្រុក ខណ្ឌ តាមការកំណត់

- ត្រូវគ្រប់គ្រង និងថែរក្សាទុកដាក់រាល់ឯកសារពាក់ព័ន្ធការងារស្ថិតិ និងអត្រានុកូលដ្ឋានឱ្យបានត្រឹមត្រូវគត់មត់ល្អ

- ត្រូវបញ្ចូលខ្លឹមសារលទ្ធផលនៃការអនុវត្តការងារស្ថិតិ និងអត្រានុកូលដ្ឋាន ទៅក្នុងរាល់ការប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងត្រូវមានវិធានការដើម្បីអនុវត្តឱ្យបានជាប្រចាំ និងបានត្រឹមត្រូវតាម ច្បាប់ អនុក្រឹត្យ សេចក្តីណែនាំ បែបបទ និងនីតិវិធីនៃការងារស្ថិតិ និងអត្រានុកូលដ្ឋាន

- ត្រូវធ្វើរបាយការណ៍ស្តីពីការងារស្ថិតិ និងអត្រានុកូលដ្ឋាន ព្រមទាំងធ្វើការបូកសរុបបញ្ហាប្រឈមនានា ដែលបានកើតឡើង ផ្ញើជូនសាលាក្រុង ស្រុក ខណ្ឌ ឱ្យបានទាន់ពេលវេលាកំណត់ ។

ខ-ហាមឃាត់នូវចង្វើមួយចំនួនដូចខាងក្រោម :

- មិនត្រូវធ្វើការកែតម្រូវបញ្ជីនៃសៀវភៅអត្រានុកូលដ្ឋានដែលបានតម្កល់ទុក ដោយមិនអនុវត្តតាមអំណាចសាលក្រមស្ថាពររបស់តុលាការ ឬតាមបទប្បញ្ញត្តិច្បាប់ ឬដោយគ្មានអំណាចសាលក្រមស្ថាពររបស់តុលាការ

- មិនត្រូវធ្វើការចេញសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមជូនប្រជាពលរដ្ឋ ដោយពុំបានចុះក្នុងបញ្ជីនៃសៀវភៅអត្រានុកូលដ្ឋាន

- មិនត្រូវធ្វើការចេញសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម និងសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទជូនប្រជាពលរដ្ឋប្រើប្រាស់ ដោយពុំបានចុះសៀវភៅអត្រានុកូលដ្ឋាន ឬពុំបានសរសេរបំពេញចូលទៅក្នុងបញ្ជីនៃសៀវភៅអត្រានុកូលដ្ឋានភ្លោះបានត្រឹមត្រូវ និងពេញលេញ

- មិនត្រូវធ្វើការកោស ឆូត លុប ប្រើទឹកលុប សរសេរជ្រៀតបន្ថែម ឬកែទិន្នន័យនៅលើសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម សេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន និងបញ្ជីនៃសៀវភៅអត្រានុកូលដ្ឋាន

- មិនត្រូវធ្វើការអូសបន្លាយដោយមិនព្រមបិទបញ្ជីនៃសៀវភៅអត្រានុកូលដ្ឋានឱ្យបានទាន់ពេលវេលាកំណត់ នាដំណាច់ឆ្នាំនីមួយៗ

- មិនត្រូវធ្វើការចុះបញ្ជីអត្រានុកូលដ្ឋានប្រភេទតែមួយ លើសពីមួយដង ឱ្យបុគ្គលតែម្នាក់ នៅក្នុងឃុំ សង្កាត់របស់ខ្លួនឡើយ

- មិនត្រូវធ្វើការចុះបញ្ជីអត្រានុកូលដ្ឋានប្រភេទតែមួយឱ្យបុគ្គលតែម្នាក់ ដែលធ្លាប់បានចុះបញ្ជីអត្រា-នុកូលដ្ឋាននៅក្នុងឃុំ សង្កាត់ផ្សេងរួចមកហើយ

- មិនត្រូវធ្វើការចុះបញ្ជីអត្រានុកូលដ្ឋានឱ្យបុគ្គលដែលមានទីលំនៅមិនពិតប្រាកដ ឬទើបមកស្នាក់នៅថ្មីក្នុងឃុំ សង្កាត់របស់ខ្លួន ដោយគ្មានឯកសារបញ្ជាក់ឱ្យបានគ្រប់គ្រាន់ ត្រឹមត្រូវ ច្បាស់លាស់

- មិនត្រូវធ្វើការចេញសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមជាលើកទី២ ទោះបីសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមដែលបានចេញលើកទី១ខូចខាត ឬបាត់បង់ក៏ដោយ

- មិនត្រូវធ្វើការទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងការចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ដោយគ្មានឯកសារសំអាងជាមូលដ្ឋានត្រឹមត្រូវ និងគ្រប់គ្រាន់

- មិនត្រូវធ្វើការចុះបញ្ជីអាពាហ៍ពិពាហ៍ មុនការចេញបានប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ និងមុនការបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍គ្រប់រយៈពេលកំណត់ ១០ថ្ងៃ

- មិនត្រូវធ្វើការទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ដោយគ្មានលិខិតជូនដំណឹងពីក្រសួងមហាផ្ទៃឡើយ

- មិនត្រូវធ្វើការចុះបញ្ជីអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស មុនការចេញលិខិតជូនដំណឹងរបស់ក្រសួងមហាផ្ទៃ

- មិនត្រូវតម្រូវឱ្យបង់ថ្លៃក្រដាស និងតែមប្រើលើសពីការកំណត់

- មិនត្រូវធ្វើការចុះបញ្ជីអាពាហ៍ពិពាហ៍ ដោយពុំមានវត្តមានសាមីខ្លួនប្តី ប្រពន្ធ និងសាក្សីជានីតិជនចំនួនពីររូប

- មិនត្រូវធ្វើការចុះបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍ និងបញ្ជាក់មរណភាព ដែលត្រូវឈប់ឱ្យប្រើប្រាស់

- មិនត្រូវធ្វើការចុះបញ្ជីមរណភាព និងចេញសំបុត្រមរណភាព ដល់ក្រុមគ្រួសារនៃអ្នកស្លាប់ដែលទុកឱ្យហួសឆ្នាំ ដោយគ្មានសាលក្រមស្ពាពរពីតុលាការ ។

II-អំពីរបាយការណ៍

យោងសេចក្តីណែនាំលេខ ០០៨ សណន ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៧ របស់ក្រសួងមហាផ្ទៃ ស្តីពីការចុះសៀវភៅអត្រានុកូលដ្ឋានឱ្យមាននិរន្តរភាព ក្រោយបញ្ចប់យុទ្ធនាការចុះសៀវភៅអត្រានុកូលដ្ឋានចល័ត បានកំណត់កាលបរិច្ឆេទអំពីការផ្ញើរបាយការណ៍ពីថ្នាក់រដ្ឋបាលមួយមកថ្នាក់រដ្ឋបាលមួយទៀតបានច្បាស់លាស់រួចហើយ ។ ម្យ៉ាងទៀតកិច្ចការនេះ សាលារាជធានី និងសាលាខេត្តមួយចំនួនធំ បានយកចិត្តទុកដាក់អនុវត្តតាមការណែនាំខាងលើបានល្អប្រសើរ ។ ទន្ទឹមនឹងនេះ ក៏នៅមានសាលាខេត្តមួយចំនួនទៀត ពុំទាន់បានយកចិត្តទុកដាក់អនុវត្តផ្ញើ៖

របាយការណ៍ឱ្យបានទៀងទាត់តាមកាលបរិច្ឆេទនៅឡើយទេ។ ហេតុនេះ ដើម្បីឱ្យការគ្រប់គ្រង ការវិភាគពីស្ថានភាពនានា នៃការអនុវត្តការងារអត្រានុកូលដ្ឋានគ្រប់ប្រភេទនៅតាមសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ សំដៅគាំទ្រ ជំរុញ និងរៀបចំផែនការយុទ្ធសាស្ត្រនានាពាក់ព័ន្ធនឹងការងារស្ថិតិ និងអត្រានុកូលដ្ឋានឱ្យបានកាន់តែល្អប្រសើរ ថ្នាក់រដ្ឋបាលនីមួយៗ ត្រូវបញ្ជូនរបាយការណ៍ពីថ្នាក់រដ្ឋបាលមួយ ទៅថ្នាក់រដ្ឋបាលមួយទៀតឱ្យបានទៀងទាត់ តាមស្មារតីនៃសេចក្តីណែនាំខាងលើ មានដូចខាងក្រោម ៖

ក- របាយការណ៍ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទ

ខ- របាយការណ៍ស្តីពីការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ

គ- របាយការណ៍ស្តីពីថវិកាដែលបានមកពីថ្លៃជាវក្រដាសអត្រានុកូលដ្ឋាន

ឃ- របាយការណ៍ស្តីពីការប្រើប្រាស់សៀវភៅ និងក្រដាសអត្រានុកូលដ្ឋាន

ង- របាយការណ៍ស្តីពីស្ថិតិប្រជាពលរដ្ឋ (ប្រចាំឆមាស និងឆ្នាំ) ។

(ដូចមានគំរូរបាយការណ៍ ចំនួន ០៥ ច្បាប់ និងគំរូលិខិតបញ្ជាក់ភាពនៅលីវ មេម៉ាយ ពោះម៉ាយ ចំនួន ០១ ច្បាប់ ភ្ជាប់មកជាមួយផង)

ទទួលបានសេចក្តីណែនាំនេះ ក្រសួងមហាផ្ទៃមានជំនឿជឿជាក់យ៉ាងមុតមាំថា អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ បន្តចាត់ចែងផ្សព្វផ្សាយ និងមានវិធានការអនុវត្តឱ្យទទួលបានលទ្ធផលល្អប្រសើរ និងមានប្រសិទ្ធភាពខ្ពស់ ។

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់អង្គភាពចំណុះទីស្តីការក្រសួងមហាផ្ទៃ
- សាលារាជធានី និងគ្រប់សាលាខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៧៩៥ ពណ.ចបព

ភ្នំពេញថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១០

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ផេស៊ីហ្វិក អឹមខេ ខមភេនី អិលធីឌី**
PACIFIC MK COMPANY LTD.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ០២៨០E/២០១០ ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១០
មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក LEE BYUNGKEUN ប្រធានក្រុមប្រឹក្សាភិបាល
លោក CHOI SONGSHIK អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៣៧៦ មហាវិថីព្រះមុនីវង្ស (៩៣) សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហារ័ណទំនិញគ្រប់ប្រភេទ - នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្តវីដេអូ
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ញើ និងចែកចាយទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ផ្លូវ

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

<u>ចម្លងជូន</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល -ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន -ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.ស.រ - ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៧៩៨ ពណ.ចបព

ភ្នំពេញថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០១០

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អ៊ីសធើន វើលវ៉ាយដ៍ ឡូជីស្ទីក (ខេមបូឌា) អិលធីឌី**
EASTERN WORLDWIDE LOGISTICS (CAMBODIA) LTD.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. ០៣៣៤ KH/២០១០** ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១០

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **អឿ សេខ យូ** ប្រធានក្រុមប្រឹក្សាភិបាល
លោក PHUA SOO NAM អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ១៣៨ FEo ផ្លូវលេខ២១៥ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ ពិសេសនាំចូលគេសជ្ជៈគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនក្នុង និងក្រៅប្រទេស
-សេវាពត៌មានវិទ្យា
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្តវីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត -ទីភ្នាក់ងារទេសចរណ៍

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ច មកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

គីម_ស៊ីថន

ចម្លងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ-កាលប្បវត្តិ

ស.ម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៩០០ **ពណ.ចបព**

ភ្នំពេញថ្ងៃទី [illegible] **ខែ** កុម្ភៈ **ឆ្នាំ ២០១០**

នេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ជេក ហូលឌីង អ៊ិនធើណេសិនណល សាមីនីង**
GEIG HOLDINGS INTERNATIONAL SAMINING Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. ០២៨១ E/២០១០** ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១០

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **FOFANA RABBI** ប្រធានក្រុមប្រឹក្សាភិបាល
លោក **OKORO IKECHUKWU SAMUEL** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៦៣ B ផ្លូវលេខ ៣២ BT សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថសំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងវេចខ្ចប់ទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ច មកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/.

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម_ស៊ីថន

ចម្លងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល -ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

៧.៨ - ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៥០១ **ពណ.ចបព**

ភ្នំពេញថ្ងៃទី ១៥ **ខែ**កុម្ភៈ **ឆ្នាំ ២០**១០

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **លី គឹមស៊ុន អ៊ីមផត អិចផត**

LY KIM SUN IMPORT EXPORT Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. ០៣២៥KH/២០១០** ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១០

មានទម្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **លី គឹមស៊ុន** ប្រធានក្រុមប្រឹក្សាភិបាល

លោក **ឡុង ទេជ្ជា** អភិបាល

លោកស្រី **ជូ សុឌី** អភិបាល

លោក **លី ខួចឡុង** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ១១៦ ផ្លូវលេខ ៣៦៩ សង្កាត់ព្រែកប្រា ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម :ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងទូរផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និង ចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដុះណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចាម ប្រសិទ្ធ

ចម្លងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិ នៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

កសន - ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៤០៧ ពណ.ចបព

ភ្នំពេញថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១០

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ខេ 2 ខេ អ៊ិនវេសមេន**
K 2 K INVESTMENT Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. ០៣០២KH/២០១០** ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១០

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **សេង ពិទូ** ប្រធានក្រុមប្រឹក្សាភិបាល
លោកស្រី **មាស សុគារ័ត្ន** អភិបាល
លោក SONG HYOUNG SEOG អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ១៦៦ E2, ១៦៨ E2, ១៧០ E2 មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ - នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដុះ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

កឹម_ស៊ីថន

ចម្លងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល -ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន -ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.ស.រ - ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៨០៥ ពណ.ចបព

ភ្នំពេញថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១០

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អរអិនអ អ៊ីមផត អិចផត**

RNR IMPORT EXPORT Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. ០៣០៨KH/២០១០** ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១០

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **មុំ សុគន្ធា**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៥៥ BEo ផ្លូវលេខ ២៤០ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម :ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និង ចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា៖ **គឹម_ស៊ីថន**

ចម្លងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិ នៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៨១៤ **ពណ.ចបព**

ភ្នំពេញថ្ងៃទី ១៥ **ខែ** កុម្ភៈ **ឆ្នាំ ២០១០**

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
សូមបញ្ជាក់ថា :

លោក **ម៉ម ចាន់ធីរះ** អភិបាលក្រុមហ៊ុន **ជី អេច មេឌា & អ៊ែតវើថាយស៊ីង ប្រូដាក់ស៊ិន**

អាសយដ្ឋាន : លេខ ៣១ F ផ្លូវលេខ ២៦៥ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

កម្មវត្ថុ : ករណីសុំប្ដូរទ្រង់ទ្រាយសហគ្រាសឯកបុគ្គល មកជា សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ។

យោង : -សំណើរបស់ក្រុមហ៊ុន ចុះថ្ងៃទី ០៨-០២-២០១០

-លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងថ្មីរបស់ក្រុមហ៊ុន ចុះហត្ថលេខា ចុះថ្ងៃទី ០៨-០២-២០១០

-សេចក្ដីប្រកាសស្ដីពីការបង្កើតក្រុមហ៊ុនក្នុងព្រឹត្តិប័ត្រពាណិជ្ជកម្ម លេខ ៤១០ ចេញផ្សាយថ្ងៃទី ១៥-០៣-២០១០

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបលោកជ្រាបថា : ក្រសួងពាណិជ្ជកម្មទទួលចុះបញ្ជីនូវការកែប្រែសហគ្រាសឯកបុគ្គល **ជី អេច មេឌា & អ៊ែតវើថាយស៊ីង ប្រូដាក់ស៊ិន G H MEDIA & ADVERTISING PRODUCTION** ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co. 2847/06I ចុះថ្ងៃទី ១៣-១០-២០០៦ និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ជី អេច មេឌា & អ៊ែតវើថាយស៊ីង ប្រូដាក់ស៊ិន**
G H MEDIA & ADVERTISING PRODUCTION Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. ០៣២១KH/២០១០** ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១០

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **ម៉ម ចាន់ធីរះ**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៣១ F ផ្លូវលេខ ២៦៥ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -សេវាផ្សព្វផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ - សេវាគូរគំនូរ រចនាផ្លាកយីហោផ្សេងៗ

-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្ដូរទំនិញ នីហ្វរ៍ណ អាហារ៍ណទំនិញគ្រប់ប្រភេទ - ទិញ លក់ កាត់កញ្ចក់គ្រប់ប្រភេទ- នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី-ផ្ទះល្វែង

-ប្ដូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

ឯវិញ្ញាបនប័ត្រ លេខ ១៤៥៩ ពណ.ចបព ចុះថ្ងៃទី ២៦-០៣-២០០៩ និង លិខិតគោលការណ៍ លេខ ២៦៤១ ពណ.នគក ចុះថ្ងៃទី ១៨-១០-២០០៦ របស់ក្រសួងពាណិជ្ជកម្មត្រូវចាត់ទុកជានិរាករណ៍ ។ លោក **ម៉ម ចាន់ធីរៈ** ត្រូវទទួលខុសត្រូវរាល់បំណុលទាំងឡាយរបស់សហគ្រាសឯកបុគ្គល ដែលកើតមានមុនការកែប្រែនេះ ។

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

...ម_ស៊ីថន

<u>ចម្លងជូន</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល -ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន -ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.ស.រ - ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៤១៥ ពណ.ចបព

ភ្នំពេញថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១០

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា ៖

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម ៖

១- នាមករណ៍របស់ក្រុមហ៊ុន : **វី សំណាង គ្រុប**

V SAMNANG GROUP Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ០៣១៤KH/២០១០ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១០

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **នូ សំណាង** ប្រធានក្រុមប្រឹក្សាភិបាល

លោកស្រី YIM VANTHA អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ១៤៦ Eo ផ្លូវលេខ ១១៨ (ក្រឡាហោមគង់) សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម ៖ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន ៖ ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និង ចែកចាយទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទនីប្រចាំឆ្នាំដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហត្ថលេខា

ចាម ប្រសិទ្ធ

កឹម_ស៊ីថន

ចម្លងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិ នៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

កសន - ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៤៦២៥ **ពណ.ចបព**

ភ្នំពេញថ្ងៃទី ១៦ **ខែ**កុម្ភៈ **ឆ្នាំ ២០**១០

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ដឹ ប្រូមីស វើលដ៍ មីសិន ខបភើរេសិន**
THE PROMISE WORLD MISSION CORPORATION Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. ០២៧១KH/២០១០** ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១០

មានទម្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក KIM JAMES NAM SOO

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៩៤៤ ផ្លូវលេខ ២១ ភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ - នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការផ្គុំសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកក់វិរជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម_ស៊ីថន

ចម្លងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល -ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន -ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាខេត្តកណ្តាល
- មន្ទីរពាណិជ្ជកម្មខេត្តកណ្តាល "មុខការ"

ស.ស.រ - ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៤៣១ ពណ.ចបព

ភ្នំពេញថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១០

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **តាវ៉ាត់សេម**
TAWATSAMB Co., Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. ០៣៣៨KH/២០១០** ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០១០
មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោកស្រី **អៀ ស្រីមុំ**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ១០.០០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៦ ភូមិបុរី១០០ខ្នង សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ - នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះ និងព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ និងពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស
-សេវាផ្នែកពត៌មានវិទ្យា
-សេវាផ្សាយពាណិជ្ជកម្ម
-ផលិតខ្សែភាពយន្ត វីដេអូ CD
-សេវាបោះពុម្ពផ្សាយ
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត - ទីភ្នាក់ងារទេសចរណ៍

-សាងសង់ ជួសជុល អាគារ ស្ពាន ផ្លូវ

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហត្ថលេខា

ចាម_ប្រសិទ្ធ

ចម្លងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល -ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន -ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.ស.រ - ឯកសារ -កាលប្បវត្តិ